**BMI0020**

# សម្ភាសន៍ជាមួយឈ្មោះ ស៊ិន ពៅ ភេទប្រុស អាយុ៤៨ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ ដឹកប្រឡាយនៅកងកុមារ

មុខងារបច្ចុប្បន្នៈ អ្នកបើកឡានធំ

ស្រុកកំណើតនៅភូមិបន្ទាយជ័យ ឃុំស្ពឺ ស្រុកចំការលើ ខេត្តកំពង់ចាម

សព្វថ្ងៃរស់នៅភូមិក្បាលស្ពាន ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ហ៊ិន សុផានី

០១ៈ៣៣ៈ០៥

៣៥ទំព័រ

ផានី ៈ ថ្ងៃនេះទី១៥ ខែតុលា ឆ្នាំ២០១០ ។ ពួកខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ពួកខ្ញុំចុះមកនេះចង់សាកសួរពូប្រវត្តិរបស់ពូ ដែលពូបានមកនៅទីនេះដំបូង កន្លែងនឹងមានការកកើតយ៉ាងម៉េចខ្លះនៅស្រុកម៉ាឡៃ ។ ហើយពូជួបហេតុការណ៍អីខ្លះតាំងពីហ្នឹងរហូតមកដល់ឥឡូវ ពូយល់ថាម៉េចដែរ ការរស់នៅហូបចុក ការងារ ។ ពួកខ្ញុំអាចសុំប្រវត្តិទាំងអស់នេះ ដែលពូនិយាយប្រាប់ពួកខ្ញុំ និងរូបថត សុំយកធ្វើជាសៀវភៅ ក៏ដូចជាសម្រាប់ក្មេងៗ និងអ្នកសិក្សាជំនាន់ក្រោយ គាត់យកទៅប្រើប្រាស់ផ្សេងៗដែរ ។ អាចយកបានទេ?

ពៅ ៈ បាទ! បាន ។

ផានី ៈ ពូមានឈ្មោះអី?

ពៅ ៈ បាទ! ខ្ញុំឈ្មោះ ស៊ិន ពៅ ។

ផានី ៈ ឆ្នាំនឹងពូអាយុប៉ុន្មាន?

ពៅ ៈ ៤៨ ឆ្នាំហ្នឹង ។

ផានី ៈ ពូមានស្រុកកំណើតនៅណា?

ពៅ ៈ ស្រុកកំណើតនៅភូមិបន្ទាយជ័យ ឃុំស្ពឺ ស្រុកចំការលើ ខេត្តកំពង់ចាម ។

ផានី ៈ ចុះរាល់ថ្ងៃពូរស់នៅកន្លែងណា?

ពៅ ៈ រាល់ថ្ងៃខ្ញុំរស់នៅភូមិក្បាលស្ពាន ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ផានី ៈ ឪពុកពូឈ្មោះអីគេ?

ពៅ ៈ ឪពុកខ្ញុំឈ្មោះ សៀន ។

ធានី : អីគេសៀន?

ពៅ : ជីតាគាត់មិនដឹងស្អីគេ ខ្ញុំភ្លេចដែរ កាលនោះយើងបែកពីគាត់នៅ ។

ធានី : អាយុប៉ុន្មានបែកពីគាត់?

ពៅ : កាលនោះអាយុ១០ឆ្នាំ១៧ឆ្នាំមិនដឹង ប៉ុនដល់ហើយយើងមិនសូវបានទៅនៅផ្ទះ ដល់អីចឹង មិនសូវដឹង កាលនោះនៅកងកុមារធ្វើការទៅ លើភ្លឺលើកទំនប់ មិនសូវដឹង ។

ធានី : ម្ដាយពូឈ្មោះអីគេ?

ពៅ : ម្ដាយឈ្មោះ ហៃ ។

ធានី : អីគេហៃ?

ពៅ : ឪពុកគាត់ឈ្មោះ លឹម ខ្ញុំវារៀងនៅស្ទើរមិនសូវច្បាស់រឿងប្រវត្តិគាត់ ។ គាត់នៅរស់ទៅ គាត់នៅសព្វថ្ងៃ ។

ធានី : គាត់នៅណាវិញ?

ពៅ : នៅភូមិខ្ញុំនឹង នៅកំពង់ចាម ។

ធានី : ពូខស្សាហ៍ទៅលេងគាត់ដែរ?

ពៅ : បាទ! ទៅបាន២ដង ។

ធានី : ចុះឪពុកពូ?

ពៅ : គាត់ខូចកាលសម័យ៣ឆ្នាំ ។

ធានី : គាត់ស្លាប់ដោយសារអី?

ពៅ : កាលនោះគាត់ ឈឺ យើងទៅដេកពេទ្យ កាលនឹងថ្នាំអីមិនសូវសំបូរ ដល់អីចឹងមើលមិនបាន ស្រួល មិនបានដិលដល់ ។

ធានី : ពូដឹងរឿងហ្នឹងនៅពេលណាដែរ ដឹងរឿងឪពុកឈឺស្លាប់នឹង?

ពៅ : ខ្ញុំនេះដែរ កាលនឹងឆ្នាំណា ខ្ញុំនៅកងកុមារទៅលើកភ្លឺស្រែ ដល់អីចឹងអត់ដឹង ខ្ញុំមកវិញ ។

ធានី : មកវិញនៅឆ្នាំប៉ុន្មានដែរ បានពូដឹងថាឪពុកពូគាត់ឈឺស្លាប់?

ពៅ : មក៧៦ ៧៧ ខ្ញុំភ្លេចហើយ ។

ធានី : ៧៦ ៧៧ ពេលនឹងបានពូដឹងថាឪពុកឈឺ?

ពៅ : បាទ!

ធានី : អត់បាននៅក្បែរគាត់ទេ?

ពៅ : អត់ទេ នៅផ្សេងៗ ជំនាន់នឹងមិនបាននៅជុំគ្នា ។

ធានី : គ្រួសារលោកពូឈ្មោះអីគេដែរ?

ពៅ ៖ ឈ្មោះ ស៊ឹម កាន់ ។

ធានី ៖ មានកូនប៉ុន្មាន?

ពៅ ៖ កូន២ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ពៅ ៖ ស្រីទាំង២ ។

ធានី ៖ ពូរៀនថ្នាក់ទីប៉ុន្មាន?

ពៅ ៖ ខ្ញុំរៀនបានទាបទេ ប៉ុន្មានដូចថ្នាក់ទី១០ ១១ពីសង្គមមុនមិនខ្ពស់អីរៀនបានតិចក៏ស្រុកយើង អីចឹងទៅ មែនទែនបានថ្នាក់ទី១០ វារកថ្នាក់មិនឃើញទេរៀនបានតិច ស្រុកគេអីចឹង ។

ធានី ៖ រៀននៅសាលាណាដែរ?

ពៅ ៖ សាលានៅភូមិ ។

ធានី ៖ ឈ្មោះសាលាអី?

ពៅ ៖ កាលនឹងអត់ទាន់មានឈ្មោះ ។ ក្រោយពីសាលានឹងទៅ ក៏យើងទៅរៀនវត្តបានតិចទៀត ។

ធានី ៖ ទៅរៀននៅវត្តណា?

ពៅ ៖ វត្តនៅបន្ទាយជ័យ ។ បាទ! វត្តនៅភូមិខ្ញុំនឹង នៅសាលាវត្តលោកបង្រៀនបានតិចយើង ស្រុកអីចឹងមកនេះ គេចេះប្រើធ្វើការទៅបែកបាក់គ្នាអស់ ។

ធានី ៖ ពូធ្វើការតាំងពីពេលណាមក?

ពៅ ៖ វាមែនទែនទៅ វាតាំងពីសម័យយើងគឺធីវើធនឹងមក នៅកងកុមារទាំងអស់គ្នា៧០ប៉ុន្មានទេ កាលនឹង ។ ដឹងថានៅ៧៨បានខ្ញុំចេញពីផ្ទះមកធ្វើកងទ័ព ។

ធានី ៖ កាលមុននឹងគឺពូនៅកងកុមារនៅជាមួយឪពុកម្ដាយ?

ពៅ ៖ បាទ!

ធានី ៖ កងទ័ពទៅណា?

ពៅ ៖ ទៅវ៉ៃនៅបូព៌ា ប្រចាំនៅស្រុកទឹកជ្រៅ ហ្នឹងកងទៅនៅនឹង ។

ធានី ៖ កងទ័ពខាងណា កងទ័ពនឹង?

ពៅ ៖ កងទ័ពកាលនឹងកងទ័ពខ្មែរក្រហម ។

ធានី ៖ តែដូចថាមេទ័ពខាងណា?

ពៅ ៖ ខ្ញុំនៅជាមួយកងពលគេឈ្មោះ តាពិន នៅមន្ទីរ ។

ធានី ៖ មន្ទីរអីគេ?

ពៅ ៖ មន្ទីរ៧០ប៉ុន្មានខ្ញុំមកនៅបានតិច ទើបឡើងពីខេត្តទៅក៏យួនវ៉ៃមក ហើយយើងកាលសម័យនឹងយើងមិនបានសូវយកចិត្តទុកដាក់អី មិនបានគិតរឿងស្អីៗ ។

ធានី ៖ ពេលពូនៅកន្លែងនឹងកងទ័ពនឹងវ៉ៃជាមួយបូព៌ា ឬវ៉ៃជាមួយវៀតណាម?

ពៅ ៖ អត់ទេ កាលនឹងវ៉ៃជាមួយវៀតណាមហើយកាលនឹង ប៉ុនយើងទើបឡើងទៅសារក្រោយ កាលនឹងគេឈ្មោះគ្នាម៉ាសារខ្មែរៗដាក់គ្នាជំនាន់សោ ភីមនឹង អត់ម៉ាសារ បានពួកខ្ញុំទៅសារក្រោយ ។

ធានី ៖ គេទៅខាងក្រោយធ្វើអីទៀត?

ពៅ ៖ ម៉ាសារក្រោយនឹងយួនៗ សារមុនជំនាន់នឹងខ្មែរប៉ះបោរម៉ាសារភាគខាងកើតប្រឈមមុខគ្នាទ័ពនឹងទ័ពម៉ាសារទៅ ដល់ពេល៧៧ម៉ាសារទៀតបានអស់ខ្មែរ បានយួនម៉ាសារទៀត ។

ធានី ៖ ម៉េចបានអស់?

ពៅ ៖ ទេ! វាមិនអស់ ប៉ុន្តែតាមព្រៃ ប៉ុនថាពួកនឹងអស់សោ ភីម ពួកនឹងស្លាប់ទៅពេលនឹង ។

ធានី ៖ ធ្វើម៉េចបានអស់សោ ភីម?

ពៅ ៖ ចុះបើកាលនោះគេបញ្ជូនទ័ពទៅច្រើន កាលនឹងទៅភាគខាងកើតនឹង ទៅវ៉ៃបូព៌ាច្រើនទៅ ប៉ុនគ្រាន់ថាកាលនឹងមានទ័ពព្រៃទ័ពអីច្រើនដែរ ។

ធានី ៖ បន្ទាប់មកទៀតទៅណាទៀត ពេលទៅវ៉ៃនឹង?

ពៅ ៖ បាទ! មិនតែមន្ទីរទេ ខ្ញុំមិនសូវដឹងដែរ ។

ធានី ៖ នៅមន្ទីរអីគេ?

ពៅ ៖ មន្ទីរនៅប្រចាំនៅទឹកជ្រៅ ខ្ញុំភ្លេចដែរ ខ្ញុំវាមិនសូវចាំដែរ ។

ធានី ៖ ហើយពូនៅធ្វើការអីនៅមន្ទីរនឹង?

ពៅ ៖ ខ្ញុំនៅនារសានឹង ។

ធានី ៖ នារសាឲ្យអ្នកណាគេ?

ពៅ ៖ នារសាមន្ទីរនឹង បើថាគេមកយកគ្រាប់នៅកំពង់ចាម ខ្ញុំជូនគេមកៗជាមួយគេ គ្រាន់គេហៅមកបានជាគ្នា គ្រាន់ជូនឡានទៅមកៗ ។

ធានី ៖ ពូអ្នកបើកឡានជូនទៅ?

ពៅ ៖ អត់ទេ ខ្ញុំជានារសា កងការពារគេទេ ។

ធានី ៖ នារសានឹងមានន័យថាម៉េច?

ពៅ ៖ នារសាដូចកងការពារ គេប្រើយើង គេទៅណាគេហៅទៅ គេត្រូវការប្រើអីគេ គេប្រើយើង ។

ធានី ៖ អានឹងកងការពារប៉ុក៏?

ពៅ ៖ អានឹងវាដូចតែគ្នា នារសា និងកងការពារ គេប្រើយើងផង យើងការពារគេផង ។

ធានី ៖ ការពារអ្នកណាគេ?

ពៅ ៖ ការពារអ្នកដឹកនាំតាមឋានៈដែលយើងនៅជាមួយគេនឹង ។

ធានី ៖ ពូនៅជាមួយអ្នកណាគេ?

ពៅ ៖ ខ្ញុំនៅជាមួយបងពើនៗគាត់នៅប្រចាំការកន្លែងឃ្លាំង គាត់អ្នកដោះស្រាយឃ្លាំងនៅកន្លែងកងពលនឹង ។ អីចឹងគាត់ត្រូវការមកយកស្អីៗ គាត់មកជាមួយខ្ញុំ គាត់ហៅខ្ញុំមក ។ កាលនឹងគាត់ជិះម៉ូតូពីក្រោយគេមក កាំភ្លើងមួយដើម ។

ធានី ៖ ហើយការពារម៉េចទៅ?

ពៅ ៖ អានឹងការពារគេហ្នឹង ដល់អីចឹងយើងស្ពាយកាំភ្លើងការពារគេទៅ ប៉ុនធម្មតាគេទៅណាគេហៅប្រើយើងទៅជាមួយគេទៅ ។ ប៉ុនពាក្យខ្មែរក្រហមគេហៅនារសាហើយ ។

ធានី ៖ នារសានឹងមានន័យថា យើងជាកងការពារគេនឹង?

ពៅ ៖ បាទ! គេត្រូវការពារគេទៅ គេត្រូវប្រើអីប្រើទៅ យើងរត់សំបុត្រឲ្យគេទៅយកទៅណាមកណាទៅ គេប្រើទៅ ។

ធានី ៖ នារសាធ្វើការគ្រប់យ៉ាង មិនមែនតែកងការពារមួយទេ?

ពៅ ៖ បាទៗ ។

ធានី ៖ បន្ទាប់មកទៀតម៉េចទៀត?

ពៅ ៖ បាទ! ខ្ញុំនៅបានប៉ុន្មានខែ យួនចូលមកខ្ញុំមកអស់ ។

ធានី ៖ ទៅណាវិញមកអស់?

ពៅ ៖ បេះនាំគ្នារត់មកតៗគ្នាមកនៅតាមព្រំដែននេះទៅ ខ្ញុំរត់ធ្លាក់មកណាម៉ាជួរភ្នំស្រង់ ក្អែកទុំបេះធ្លាក់មកនេះមក ខ្សាច់កាត់ភ្នកនឹង ធ្លាយមក ។

ធានី ៖ កាលនឹងពូរត់ពីណាមកមុនគេ ដំបូង?

ពៅ ៖ ខ្ញុំចេញពីនេះមក យួនមកស្ទាក់ផ្លូវនៅមេម៉ត់ នៅក្រែក នៅស្អីត្រង់ណាមកតាមផ្លូវនេះដល់ហើយវាងចេញមកអូររាំងឪ ធ្លាក់មកអ្នកលឿង បានចេញផ្លូវជាតិលេខ១ ឡើងមកភ្នំពេញវិញ ។

ធានី ៖ ដេញបញ្ច្រាសមកវិញ?

ពៅ ៖ បាទ! ត្រឡប់មកនេះវិញ ផ្លូវជាតិលេខ១យួនឡើងមកក្រោយទេ ។

ធានី ៖ ហើយម៉េចទៀត?

ពៅ ៖ ដល់ដេញទៀត ខ្ញុំហែលទឹកឆ្លងទន្លេក្រោមស្ពាន ឆ្លងមកតាខ្មៅមក ទើបនៅផ្លូវជាតិលេខ២ បានប៉ុន្មានថ្ងៃ យួនបន្ថែម៥កងពលមកទៀត គេនាំមកទៀតបង។ ហើយយើងប្រជាជនគាត់ហៅមកនៅជាមួយ ។ ប៉ុនបង។គេបបួលយួនគេវះពោះ វះអីចេះមកតាមគាត់ទៀតទៅ ហើយខ្លះគេបានប្រពន្ធបានអីនៅនឹងទៅ ។ ហើយយើងគេបបួលមកនៅស្ទើរដែរ ដល់គេចេះបបួលមកតាមគេ ឆ្លងផ្លូវជាតិលេខ៣ លេខ៤ចេះមក ។

ធានី ៖ ចេះឆ្លងកាត់រហូតទៅដល់ណា?

ពៅ ៖ បាទ! បានមកប៉ះកម្លាំងធំគេមកពីបូព៌ា នៅនេះ ដល់អីចឹងគេដើរតាមគេ។ វ៉ៃម៉ាជួរភ្នំស្រង់ក្អែកទុំ ។

ធានី ៖ ប៉ះកម្លាំងអ្នកណាគេ?

ពៅ ៖ កម្លាំងពួកខ្មែរក្រហម ប៉ុនកម្លាំងធំគេនឹង ក៏នៅជាមួយគេនឹង ដល់ហើយគេដើរវ៉ៃម៉ាជួរនឹងវ៉ៃ។ ទាល់តែអស់បន្លែកអស់ទីពឹងមិនដឹងទៅណាទៀត បានចេះតែមកលិចមកទៀត ។

ធានី ៖ វ៉ៃអស់អី អស់កងទ័ព ឬអស់អី?

ពៅ ៖ អស់គ្រាប់ អស់ស្បៀងយើងរកលែងកើត វាអត់អីហូបអត់អីនេះហើយចេះមកត។គ្នា នាំគ្នារត់មកនឹង លែងតគ្នា ។

ធានី ៖ ពេលនឹងរត់វិញ លែងតាមគេតាមឯង?

ពៅ ៖ បាទ!

ធានី ៖ របៀបមកតាមគេដែរ?

ពៅ ៖ បាទ! ចេះមកតាមគេហ្នឹង ។

ធានី ៖ ម៉េចដែរពេលរត់ពេលអីនឹង ហើយមកដល់ជួបគ្នាជួបអី?

ពៅ ៖ បាទ! គេចេះស្ទាក់វ៉ៃតដែរ ។

ធានី ៖ ពូចេះវ៉ៃដែរ ក្រែងពូប្រាប់ដំបូងនៅមន្ទីរអត់នៅណា?

ពៅ ៖ ដល់ពេលនឹងគេឲ្យកាន់កាំភ្លើងហើយ ពេលនឹងយើងមក កាលមុនក៏យើងកាន់គ្រាន់ថាយើងមិនទៅបាញ់ទៅបោះទេ ។ ដល់ពេលមកអីចឹងយើងត្រូវវ៉ៃបំរាស់ហើយពេលនឹង បើយើងមិនបាញ់គេ គេបាញ់យើងពេលនឹង ។ ត្រូវតែប្រឹងប្រែពេលនឹង ពេលណាយើងគេចរួចគេចយើងតបានក៏តទៅដើម្បីគេចខ្លួនដើម្បីរស់ ។ ហើយយើងមកដល់ព្រំដែននេះ កាលនឹងវាមនុស្សងាប់នឹងព្រំដែន ងាប់នឹងដាច់បាយ គ្មានអ្នកណាយកអ្នកណាដេកម៉ាកន្លែងព្រឹកឡើងអ្នកណាទៅរួចចេះទៅ អ្នកណាទៅមិនរួចចេះនៅ ។

ធានី ៖ ម៉េចដែលពូមានអារម្មណ៍ម៉េច?

ពៅ :	វារន្ធត់ដែរ ត្រង់ថាយើងមិនដឹងធ្វើម៉េច វាអត់ជួយគ្នាបាន វាមិត្តល្អគ្នាស្រឡាញ់ប៉ុន្មាន ប៉ុនដល់ពេលនឹងជួយគ្នាលែងបាន វាអស់រៀងខ្លួនហើយ ។ ចុះគ្មានអីហូបខ្លួនទទេររៀងខ្លួន ។

ធានី :	មកដល់នឹងម៉េចបានអត់បាយ?

ពៅ :	ចុះមកដល់ដំបូងចេះមកត ៗ មកដល់ព្រំដែននេះយើងចេះមកត អត់ទាន់មានអ្នកណាគេជួយទេ អាពេលនឹងវាដាច់អាពេលនឹង ដល់កាកបាទវាមកក្រោយទេ ។ ដល់កាកបាទមកឃើញជួយបានអូសទៅ កាលនឹងគេហៅរដ្ឋាភិបាលទាក់ទងថៃបានមានជំនួយបានចងក្រងជាអង្គភាព យើងមានរបបហូបចុកគ្រប់គ្រាន់ បាននៅបានសល់ពូថ្ងៃ ។

វនី :	ដល់ពេលមកដំបូងដាច់បាយស្លាប់ច្រើន?

ពៅ :	ច្រើនណាស់ អ្នកនៅនេះរស់តិចទេ អ្នកនៅនេះងាប់ច្រើនជាង ។

ធានី :	ភាគច្រើនអ្នកមកដល់នឹង មានចំនួនប៉ុន្មាននាក់ទៅមកដល់ម៉ាឡៃហើយមានបញ្ហាដាច់បាយស្លាប់?

ពៅ :	ខ្ញុំអត់ដឹងទេ កាលនឹងមនុស្សវាច្រើនដែរ កាលនឹងពួកបារាំង ៗ ដែលគេមកយកទៅជំរំនឹងច្រើនដែរ ។ គេដើរប្រមូលយក អាខ្លះឃើញដួលឃើញដេក ឃើញឈឺក៏គេអូស គេគ្រាលយកទៅពួកបារាំងនឹង ។ ហើយដល់អីចឹងគេកែណ្ឌ គេយកទៅដែរនឹង ប៉ុនយើងអត់ទៅ ។

ធានី :	ហេតុអីកាលនឹងអត់ទៅ?

ពៅ :	វានឹកឃើញថាបើសិនណាជាទៅ យើងខ្លាចមិនបានវិលមកវិញ យើងអត់ហ៊ានទៅ ។

ធានី :	ទៅណា?

ពៅ :	ដឹងគេថាទៅជំរំទៅក្រៅទៅឆ្ងាយ ហើយយើងនឹកឃើញទៅឆ្ងាយទៅ យើងខ្លាចវិលមកស្រុកវិញអត់បាន ហើយចេះនៅក្រាញ់ ។

ធានី :	នៅពេលណា នៅពូឆ្នាំប៉ុន្មាន?

ពៅ :	៧៩ ។

ធានី :	នៅព្រៃស្ទុង ឬក៏ម៉េច?

ពៅ :	ព្រៃស្ទុងមានអីតាមនេះ មានព្រៃស្ទុង ។

ធានី :	ហើយមកនៅក្នុងព្រៃបានអីហូប បានអីស្នាក់នៅម៉េច?

ពៅ :	ដំបូងយើងមកដល់ដំបូងដែលអត់អីស៊ីខ្លាំង ដែលដើរបានរកបានយើងទៅដីថៃ ។

ធានី :	ដើរទៅដីថៃ?

ពៅ :	បាទ! ឆ្លងទៅដីថៃមានអីហូបហើយ អំពៅ ពោត ដំឡូងគេ អត់សល់ទេដកខ្ទេចខ្ទី ។ បើមិនអីចឹងមានអីហូប ទម្រាំបានគេជួយ យើងបានរស់ ។

ធានី ៖ អ្នកណាដែលមានកម្លាំង យើងមានពោត ដំឡូង ញ៉ាំ អ្នកណាអត់កម្លាំងអត់ដឹងធ្វើម៉េចទេ?

ពៅ ៖ បាទៗ ។

ធានី ៖ អ្នកណាអត់កម្លាំង គេអត់បានអីហូបអត់ស្លាប់ទៅ?

ពៅ ៖ បាទ! ទៅបានមកខ្លះមក អ្នកនៅបានហូបទាំងអស់គេ ។

ធានី ៖ តែនៅអត់គ្រប់គ្រាន់ដែរ?

ពៅ ៖ បាទ! អត់គ្រប់គ្រាន់ទេដំបូង វាអត់ទាន់មានអី ហើយខ្លះបងនារីៗគេស្អាតខ្លះថៃយើញមកគេនាំទៅ បានអង្ករបានអីហូប ខ្លះក៏គេបានគ្នារហូតទៅ ខ្លះគេមានមាស មាននាឡិកាដូរអង្ករតិចៗទៅ ។

ធានី ៖ កាលនឹងសុទ្ធតែព្រៃទាំងអស់?

ពៅ ៖ ព្រៃអត់មានអីទេ ។

ធានី ៖ ហើយយើងដើរកាត់ព្រៃនឹងទៅដល់ទល់ដែនថៃដើម្បីឆ្លងដូរចុះដូរឡើងហូប?

ពៅ ៖ បាទៗ ។

ធានី ៖ ពេលដែលពូមកថាឆ្លងកាត់ព្រៃ តើមានសត្វមានអីអត់?

ពៅ ៖ ហ៊ើ! សត្វសំបូរណាស់កាលនឹង យើងនៅនេះរស់ដោយសារសត្វ រស់ដោយយើងអត់មានលុយកាក់ទិញយើងនៅព្រៃនឹងបានបាញ់សត្វហូបហើយ ។

ធានី ៖ ម៉េចពូថានៅតែអត់អីហូប?

ពៅ ៖ អត់ទេ វាអត់៩បាយ តែរឿងសត្វព្រៃយើងអត់ខ្វះហូបទេ សំបូរណាស់សត្វនៅនេះ ។

ធានី ៖ អត់បាយក៏អាចធ្វើឲ្យមនុស្សស្លាប់ដែរ?

ពៅ ៖ បាទ!

ធានី ៖ ទោះមានសត្វហូបក៏ដោយ?

ពៅ ៖ បាទ! វាហូបវាមិនដូចបាយ និយាយទៅវាហូបមិនគ្រប់គ្រាន់ ។ កាលនឹងយើងចេះតែរត់មក សត្វនឹងយើងហូបបានម្តងៗ ប៉ុនបើឲ្យហូបប្រចាំថ្ងៃវាមិនមានទេ ព្រោះយើងរត់នោះ ។

ធានី ៖ រត់ពីណាដល់ណា បានរត់រហូតចុះឡើងៗ?

ពៅ ៖ វាមែនទែន តាំងពីឃ្លួនចូល ព្រោះខ្ញុំនៅព្រំដែនឯកើត តាំងពីនឹងមករហូត ។

ធានី ៖ ចង់ថាមកដល់នេះពូរត់ចុះឡើងយ៉ាងម៉េចខ្លះទៅ?

ពៅ ៖ មកដល់នេះ យើងរត់ពេលយួនមកដល់ ពេលណាយើងរត់ឆ្លងដីថៃទៅ ពេលណាដែលយើងវៃបាន យើងចូលមកតិចមក ។

ធានី ៖ ពេលណាដែលមានយួនវៃចូលមក?

ពៅ ៖ យួនតាមដេញមករហូត ។

ធានី ៖ តាមដេញមករហូត?

ពៅ ៖ បាទ! ដែលយើងអត់ត ចុះមានអីតបើយើងរកដើរតែខ្លួនមិនរួចហើយ គេចេះមកតាមក្រោយរហូត ដួនកាលយើងនៅជុំគ្នា ទុងទាំងពីក្រោយមកយើងចេះទៅទៀតហើយ ។

ធានី ៖ កាលនឹងឆ្នាំប៉ុន្មាន ៧៩ដដែល?

ពៅ ៖ បាទៗ ។

ធានី ៖ ដល់ឆ្នាំប៉ុន្មាន បានឮថាមានអីហូបចុកគ្រប់គ្រាន់?

ពៅ ៖ បាទ! វាជិតដល់ចូលឆ្នាំ៨០ហើយ អានឹងបានវាមានជំនួយមានអីដែលចូលឆ្នាំ៨០ គេរៀបចំកម្លាំងបានអស់ចងក្រុងជាក្រុមជាកង នឹងច្បាំងតបតវិញបានហើយ ។ ប៉ុនកាលពីដំបូងមកនៅដាច់ដោច មិនដឹងអ្នកណាអ្នកណែចេះប្រមូលគ្នាមក មិនដឹងកងណាៗចេះនៅ ។

ធានី ៖ អ្នកណាគេអ្នកចងក្រុងកម្លាំងនឹង?

ពៅ ៖ វាមែនទែន គេមេដឹកនាំវាមានហើយ ប៉ុនយើងសម្រាប់នៅក្នុងមកជាមួយគ្នា គេចេះចងក្រុងគ្នាយើងទៅណា ។ មេៗណាគេធ្លាប់ដឹកនាំចាស់ៗ ក៏គេចេះប្រមូលកម្លាំងតៗគ្នា ។

ធានី ៖ អ្នកណាគ្រប់គ្រងធំនៅនឹង ប្រមូលកងដែលពូនិយាយដែលថាមានចំនួនដូចពូនិយាយនឹង?

ពៅ ៖ នៅយើងនេះ កាលនឹងមកដល់នេះមានមេមានកើយនៅនេះហើយនៅម៉ាឡៃ ។ ប៉ុនបើមកតាមផ្លូវចេះមកតគ្នាមិនដឹងអ្នកណាអ្នកកងអ្នកណា ប៉ុនមកដល់ម៉ាឡៃនេះ មានមេធំៗគាត់នេះហើយ ។

ធានី ៖ មេធំៗនឹងអ្នកណាគេខ្លះ ដែលគាត់មកពីអង្គាល់ណា?

ពៅ ៖ អត់ទេ មកជាមួយគ្នាទាំងអស់ ។

ធានី ៖ មេធំៗដែលរត់មកដែរនឹង?

ពៅ ៖ បាទ!

ធានី ៖ អ្នកណាគេទៅ?

ពៅ ៖ មកនេះទៅមានអ៊ីវ៉ាន់ អ៊ីអ៊ីនឹង គាត់នៅប្រចាំនៅនេះ ។

ធានី ៖ អីគេវ៉ាន់?

ពៅ ៖ តាអៀង សារី ។

ធានី ៖ អ៊ំវ៉ាន់ ឈ្មោះ អៀង សារី?

ពៅ ៖ បាទៗ ។

ធានី ៖ គាត់អ្នកចងក្រងកងពលអីនឹង?

ពៅ ៖ បាទ! កងពលមានតាហុង តាភាព កាលនឹងពួកគាត់នៅកន្លែងទទួលភ្ញៀវ ។

ធានី ៖ តាហុងនឹងអ្នកកន្លែងទទួលភ្ញៀវ?

ពៅ ៖ គាត់នេះ កន្លែងទទួលភ្ញៀវ គាត់នឹងមេ មកនៅនេះគាត់កងពល ។

ធានី ៖ តែកាលមុនគាត់នៅណា?

ពៅ ៖ គាត់នៅភ្នំពេញ នៅកន្លែងភ្ញៀវ ។

ធានី ៖ ហើយអ៊ំវ៉ាន់នឹង គាត់អ្នកចងក្រងទ័ពឡើងវិញ?

ពៅ ៖ បាទ! ដែលវាបែកបាក់គ្នាទៅ គាត់មកឈរជើង គាត់ប្រមូលតៗ ។

ធានី ៖ គេប្រមូលមុនៗនឹងហើយ គ្រាន់គាត់អ្នកចងក្រង?

ពៅ ៖ បាទ! វាមកៗទាំងអស់គ្នា ប៉ុន្តែគ្រាន់មកដល់មុន មកដល់ក្រោយ ។

ធានី ៖ អ្នកណាមកមុនចងក្រងមុនទៅ អ្នកណាមកក្រោយចងក្រងក្រោយ?

ពៅ ៖ បាទ! មកតៗគ្នាទៅ ។

ធានី ៖ មិញពូថាអ៊ំវ៉ាន់ តាហុង តាភាពនឹង គាត់ម៉េច?

ពៅ ៖ គាត់នៅ ចុះមេៗអ្នកដឹកនាំនៅនេះ ។

ធានី ៖ នៅនេះមានអ៊ំវ៉ាន់ តាហុង តាភាព?

ពៅ ៖ បាទ! អានឹងគាត់មេៗតគ្នា ប៉ុន្តែពីលើមកមានអ៊ំវ៉ាន់នឹងឯង គាត់អ្នកគ្រប់គ្រងនេះជាប់ ។

ធានី ៖ តាហុងនឹងអ្នកណាគេ?

ពៅ ៖ គាត់នៅនេះរាល់ថ្ងៃ ។

ធានី ៖ គាត់នឹងជាអ្នកណាគេ ៧៩?

ពៅ ៖ គាត់នឹងគ្រប់គ្រងខាងក្រោមគណៈធិបតីស្រុកម៉ាឡៃមានគាត់នឹង ។

ធានី ៖ តាហុងនឹង?

ពៅ ៖ បាទ!

ធានី ៖ ចុះតាភាព?

ពៅ ៖ តាភាពគាត់ខាងកងពល ខាងកងទ័ពនឹងដែរ ។

ធានី ៖ ពីរនឹងមួយណាធំ?

ពៅ ៖ កាលនឹងនៅម៉ាឡៃដំបូងមានពូហុងធំជាងពូភាព ។

ធានី : ចុះឥឡូវ?

ពៅ : ឥឡូវពូភាពគាត់ឡើងទៅផុតហើយ ពូហុងគាត់នៅនេះ ។

ធានី : ពូហុងនឹងគាត់ធ្វើអីរាល់ថ្ងៃ?

ពៅ : អត់ធ្វើអីទេ មែនទែនគាត់សម្រាកហើយ ព្រោះរដ្ឋាភិបាលបំពាក់ផ្កាយគាត់ដែរ ប៉ុនបើយើងចាស់ជង ហើយយើងទៅធ្វើអីកើត ដាំដំណាំនៅនេះ ។

ធានី : ផ្ទះគាត់នៅកន្លែងណា?

ពៅ : នេះកូនចៅគាត់នៅតែមួយកន្លែងនៅជិតផ្ទះយាយបូ ខាងក្រោយនេះ ឥឡូវគាត់ចេញទៅនៅក្រៅ ឲ្យកូននៅ ។

ធានី : ក្រៅកន្លែងថ្នល់នឹង?

ពៅ : ទៅនៅក្រោឯចុងជិតកន្លែងលក់ប្រេង នៅជិតរោងវែងធំមកខាងនេះតិច ផ្ទះគាត់ដំណាំពេញ ។

ធានី : គាត់នៅផ្ទះ?

ពៅ : បាទ! គាត់នៅ២នាក់យាយតា ។

ធានី : អ៊ីវ៉ាន់គាត់ប្រមូលហើយ បន្ទាប់មកគាត់បែងចែកយ៉ាងម៉េច ការរស់នៅគ្រប់គ្រងយ៉ាងម៉េច?

ពៅ : គ្រប់គ្រងកាលនឹងនៅកន្លែងនេះ វាមែនទែនកន្លែងវាធូរស្រាលជាងគេនៅស្រុកម៉ាឡៃ បើនិយាយពីរបបកុម្មុយនីសកាលជំនាន់នឹង ។ ព្រោះកន្លែងនេះវាភ្ញៀវចេញចូលច្រើនប្រជាជនរស់នៅវាអត់សូវតឹងដូចខាងតំបន់ផ្សេងៗទេ ព្រោះអីមានភ្ញៀវបរទេសចេញចូលច្រើនប្រជាជនគេបន្ធូរតិចដែរកាលជំនាន់នឹង ។

ធានី : ភ្ញៀវខាងណាមក?

ពៅ : ភ្ញៀវបរទេសច្រើនដែរ ចេញចូលប្រចាំថ្ងៃ ។

ធានី : ចេញចូលមកនឹងធ្វើអី?

ពៅ : បាទ! អត់ដឹងគេមកទំនាក់ទំនងរឿងអី យើងអត់ដែរ ទំនាក់ទំនង ។

ធានី : ទំនាក់ទំនងជាមួយអ្នកណាគេ?

ពៅ : ជាមួយមេៗដឹកនាំខ្មែរក្រហម ។

ធានី : អ្នកណាគេខ្លះទៅ?

ពៅ : បាទ! ខ្ញុំអត់សូវច្បាស់ដែរ ប៉ុនឃើញភ្ញៀវចេញចូលជាប្រចាំដែរ ព្រោះកាលនឹងយើងអត់សូវដឹងរឿងនយោបាយ ព្រោះយើងខាងក្រោមៗ រឿងជ្រៅខាងលើ យើងមិនសូវ

ដឹងទេ ប៉ុនយើងឃើញភ្ញៀវចេញចូលរាល់ថ្ងៃ។ ព្រោះខ្ញុំនៅកងពិសេសនៅខាងត្បូង ខ្ញុំជូនភ្ញៀវជាប្រចាំដែរ។

ធានី : ពួអ្នកជូន?

ពៅ : បាទ! ខ្ញុំនៅកងពិសេស។

ធានី : កងអីគេ កងពិសេស?

ពៅ : កងពិសេសកង ដូចថាគេរៀបចំកងពល គេមានកងពិសេសម៉ាវរសេនាតូច គេសម្រាប់ដូចត្រង់ណាពិបាកវ៉ៃ ពិបាកអីគេឲ្យយើងទៅវ៉ៃទៅ។

ធានី : កងពិសេសនឹងម៉េចទៅទទួលភ្ញៀវ?

ពៅ : បាទ! ពេលណានេះភ្ញៀវមកអីចឹង យើងជូនភ្ញៀវចុះឡើងដែរ។

ធានី : ជូនភ្ញៀវទៅណា?

ពៅ : ជូនភ្ញៀវដូចថាឥឡូវគេចូលតាមច្រកម៉ាឡៃនឹងទៅដល់សំពៅលូន គេដើរទស្សនកិច្ចអីទៅយើងជូនគេទៅ ជូនគេមកវិញ គេស្នាក់ប៉ុន្មានយប់ តាមព្រំដែន។

ធានី : ដើរទស្សនកិច្ចម៉េចទៅ បើអត់មានអីផង សុទ្ធតែព្រៃនឹង?

ពៅ : បាទ! ព្រៃ ប៉ុនគេដើរមើលតំបន់ខ្មែរក្រហមរស់នៅ ហើយកាលវ៉ៃគ្នាយ៉ាងម៉េចៗ ជូនកាលគេមកថតសមរភូមិវ៉ៃគ្នាយ៉ាងម៉េចៗ គេមកថត។

ធានី : ហើយអ្នកមកទស្សនកិច្ចនឹងជាអ្នកណាគេ ជនជាតិអីទៅ?

ពៅ : ច្រើនដែរ កាលនឹងច្រើនប្រទេសដែរ ដល់អីចឹងយើងចាំមិនអស់ទេ។

ធានី : មើលទៅជនជាតិអីគេ?

ពៅ : មានស្បែកខ្មៅ ស្បែកស ខ្ញុំមិនសូវជាចាំដែរ កាលនឹងខ្ញុំវាមិនសូវយកចិត្តទុកដាក់ដែរ។

ធានី : គ្រាន់ដឹងថាជូនភ្ញៀវ?

ពៅ : បាទ! ដឹងថាជូនភ្ញៀវ យប់ឡើងគេដេក យើងនៅដេកខាងៗ។

ធានី : ដេកជុំវិញនឹងទៀតការពារទៀត?

ពៅ : បាទ! ការពារគេ កុំឲ្យគេខ្លាច កុំឲ្យគេបារម្ភ។

ធានី : ភ្ញៀវមកអីចឹង មានអ្នកគេចេះភាសា?

ពៅ : បាទ! មាន។

ធានី : អ្នកណាគេទៅ?

ពៅ : វាមានច្រើនដែរ កាលនឹង មានពួកពេទ្យអីគេមកបង្រៀនដែរ។ ហើយភាសានឹងពីណាខ្លះកាលនឹង ជំទុកយើងក៏បកប្រែដែរ។

ធានី ៖ ជិទុកទី១ឃុំ?

ពៅ ៖ បាទ! កាលនឹងគាត់ដើរតែជាមួយភ្ញៀវដែរនឹង តែមានភ្ញៀវមកឃើញគាត់ដើរជាមួយ ។

ធានី ៖ គាត់បកប្រែឲ្យបរទេសនឹងដែរ?

ពៅ ៖ បាទ! ហើយខ្ញុំនៅឆ្ងាយខ្ញុំមិនសូវដឹង ព្រោះយើងការពារ យើងមិនបានស្និតទេ ។

ធានី ៖ មើលពីចំងាយមើលគេមើលឯង?

ពៅ ៖ ព្រោះយើងទៅមុន ឬទៅក្រោយទេ ឬទៅអីយើងមិនសូវដឹងទេ ។ ប៉ុនគេឲ្យជូនទៅណា យើងទៅមុន នៅក្រោយគេ ។

ធានី ៖ ភ្ញៀវខស្សាហ៍មកញឹកញាប់ខ្លាំង?

ពៅ ៖ ញឹកណាស់ បើនិយាយមែនទែនសឹងរាល់ថ្ងៃ ។

ធានី ៖ ឆ្នាំប៉ុន្មាន?

ពៅ ៖ មែនទែនតាំងពីយើងមកនៅនេះ ភ្ញៀវចេញចូលរហូត ។

ធានី ៖ ៩០ជាង ឬ៨០ជាង?

ពៅ ៖ បាទ! បើចាត់មែនទែន ត្រឹម៨០នឹងភ្ញៀវមករហូត ។

ធានី ៖ ៨០ហ្នឹងមានភ្ញៀវមកហើយ?

ពៅ ៖ បាទ! ត្រង់ណាដែលផ្លូវលំបាកខ្លាំង កាលនោះដំរី ជិះដំរីខ្លះអីខ្លះទៅ ។

ធានី ៖ មានជិះដំរីមកទៀត?

ពៅ ៖ បាទ! ដំរីយើងនៅនេះចាំទទួលគេ ។

ធានី ៖ នៅស្រុកយើងមានដំរីដែរ?

ពៅ ៖ បាទ!

ធានី ៖ នៅព្រៃនឹង?

ពៅ ៖ បាទ! ដំរីដែលយកកាលយើងរត់មកនោះ ។

ធានី ៖ រត់យកដំរីមកជាមួយដែរ?

ពៅ ៖ បាទ! មានដំរីមកជាមួយ ។

ធានី ៖ មានប៉ុន្មានគ្រឿង(ក្បាល)?

ពៅ ៖ ហ៎! កាលមកមានច្រើនដែរ តែដល់ក្រោយមកងាប់អស់ទៅ ត្រូវមីនខ្លះ ត្រូវអីខ្លះ យើងដឹកគ្រាប់ទៅមុខខ្លះ ពេលណាពិបាកទៅជួយដឹកគ្រាប់ទៅដែរ ។

ធានី ៖ ដំរីវាជួយច្រើនយ៉ាង?

ពៅ ៖ ជួយ ហើយនៅនេះចងនៅដីថៃៗលួចអស់មួយ ។

ធានី : ចង់ទៅគេលួចយក?

ពៅ : បាទ! ថៃលួចយក ។

ធានី : មកយើងចង់ក្បែរនឹងពេក?

ពៅ : ចុះកាលនឹងយើងអត់មានវាលទេ មានតែព្រៃ ដល់ដីថៃវាវាល ។ ខ្មោចតាម៉ននៅជិតវត្ត គាត់យកទៅចង់ឲ្យស៊ីនៅនឹង យើងមកកន្លែងនឹងទៅវិញបាត់ ។

ធានី : ហើយពួកគាត់ថាម៉េចទៅបាត់ដំរីមួយ?

ពៅ : បាត់ថាម៉េច បើដំរីបាត់ហើយ យើងទៅតាមរកម៉េចស្រុកគេវាពិបាក ។

ធានី : ដំរីប៉ុនណាណៃរកមិនឃើញម៉េច?

ពៅ : ចុះស្រុកគេយើងម៉េចហ៊ានទៅរកណា ញ៉េរញ៉ៃកាលនឹង ។ ដឹងគេយកហើយ មិនដឹងទៅតាមនៅណា ។

ធានី : ដំរីស្គាល់ផ្ទះ ស្គាល់អី?

ពៅ : អត់ស្គាល់ទេ គេហ្វ(ហ្វដំរី) គេច្បាស់ដែរ គេអ្នកមកយក ។

ធានី : មានហ្វដំរី?

ពៅ : ហ្វដែលគេមកយក គេអ្នកលួច តាមមើលយើងឲ្យស៊ីនៅនឹងរាល់ថ្ងៃគេដឹង ដំរីយ៉ាងម៉េចៗ ថ្ងៃណាយើងស្វាត់ គេលួចទៅ ។

ធានី : យើងទៅតាមព្រំដែននឹងរហូត ម៉េចបានគេលួចបាន?

ពៅ : ចុះយើងចង់ឆ្ងាយពីព្រំដែនដែរ ។

ធានី : ដំរីតែដាក់មិនស្រួលគេយកបាត់ ។ ដំរីនៅនឹង កាលនឹងគេយកមកប៉ុន្មានក្បាល?

ពៅ : កាលជំនាន់នឹងមកច្រើន ដល់ក្រោយមកវាទៅវិញខ្លះ ងាប់ខ្លះតៗនៅសល់៤-៥ក្បាលនៅនេះ ហើយដល់ក្រោយមកវាចេះងាប់បន្តៗ ។

ធានី : ថីបានវាងាប់?

ពៅ : មិនដឹងម៉េចដែរ ជាប់អូរដំរីគ្រុនអី កូនដំរីអីដឹកគ្រាប់ទៅ ។

ធានី : កន្លែងដាក់កូនដំរីនឹងសុទ្ធដែរ?

ពៅ : អត់ទេ អានឹងកូនដំរីនឹងខាងនេះផ្សេងទេ ហៅអូរដំរីគ្រុនទៅដល់នឹងដំរីវាអត់ស្រួលខ្លួនវាដល់អីចឹងជាប់អូរដំរីគ្រុន ។

ធានី : ដំរី ដល់ពេលវាឈឺស្លាប់ច្រើន ប្រហែលជាប៉ុន្មានក្បាលពូស្មាន ដែលវាមាននៅស្រុកយើងពេលតាំងពីមក? ហើយយកមកពីណាដំរីនឹង?

ពៅ : ដំរីនឹងកាលពេលយើងរត់យួនមក យកមកជាមួយ ។

ធានី ៖ ពូដឹងថាមកពីខាងណាៗ?

ពៅ ៖ ខ្ញុំអត់សូវដឹងទេ ខ្ញុំទើបមក ដល់វត់មកបានឃើញប៉ះមក ឃើញគេមានដំរីមានអី ប៉ុនយើងវាមិនច្បាស់ថាប៉ុន្មានៗឲ្យដាក់យើងអត់ដឹងទេ ។

ធានី ៖ គ្រាន់ដឹងថាមានដំរី?

ពៅ ៖ បាទ!

ធានី ៖ ហើយដំរីនឹង យកវាមកដើម្បីធ្វើអីខ្លះ?

ពៅ ៖ បើយើងនៅប្រចាំនេះ មានអី បើមែនទែនដឹកភ្លៀវខ្លះទៅ ប្រើការដឹកគ្រាប់ជញ្ជូនគ្រាប់អង្ករទៅមុខទៅ ជួយបានច្រើនដែរ មនុស្សខ្លះ សត្វខ្លះចេះជួយរួមចំណែកគ្នាទៅ ។

ធានី ៖ ពេលខ្លះមនុស្សដឹកគ្រាប់ដឹកអង្ករ ដឹកស្បៀង ដល់ពេលខ្លះដំរី?

ពៅ ៖ បាទ! ជួយគ្នា ។

ធានី ៖ មិនមែនពេលប្រញាប់ដំរីដឹកទេ ឬពេល?

ពៅ ៖ អត់ទេ អានឹងទៅតាមដំណើរទាំងអស់គ្នា ពេលណាដែលត្រូវថាវៃធំដុំ ក៏ដឹកគ្រាប់មិនទាន់ ក៏ចេះជួយគ្នាទៅ ប្រមូលកង់ទ័ពអ្នកនៅក្រោយនឹងជួយខ្លះ ប្រជាជនខ្លះ សិស្សសាលាខ្លះចេះជួយគ្នា ដើម្បីឲ្យទាន់សភាពការណ៍ ។

ធានី ៖ ហើយកាលនៅនឹងមកដំបូងមានប្រហែលមានមនុស្សប៉ុន្មាននាក់នៅស្រុកនឹង?

ពៅ ៖ ស្រុកម៉ាឡៃ ពីដើមមិនច្រើនប៉ុន្មាន នៅតិចដាងគេតាមបណ្តោយព្រំដែន គិតស្រុកម៉ាឡៃតិចជាងគេ ។

ធានី ៖ ប្រហែលមនុស្សប៉ុន្មាននាក់ទៅ?

ពៅ ៖ កាលនឹងវាត្រូវមកប៉ុន្មាន វរសេនាធំ ព្រោះអីខ្ញុំនៅក្រោយគេដែរ ។ ហើយប្រជាជនយើងទើបមកច្រើនកាលយើងបែកជំរំឆ័ត្រ នៅនេះចាស់ម៉ង ប្រជាជនមិនសូវច្រើនប៉ុន្មានទេ ។

ធានី ៖ តិចដែរ?

ពៅ ៖ បាទ! តិចដែរ ក្រោយមកបានទៅចូលជំរំចូលអី ខ្លះទៅជំរំ ខ្លះទៅនេះទៅនោះ ។

ធានី ៖ ជំរំនៅណា?

ពៅ ៖ កាលមុនដំបូងជំរំនេះមានតែខាវអ៊ីដាង ។

ធានី ៖ ខាវអ៊ីដាងតាមស្រុកម៉ាឡៃយើងទៅ?

ពៅ ៖ បាទ!

ធានី ៖ មានជំរំអីទៀត?

ពៅ ៖ ដល់ពេលក្រោយមកទៀត បានបែកធំកាលឆ្នាំណាជំរំធំមានជំរំតាង៉ុក ។

ធានី ៖ អានឹងជំរំអីគេ?

ពៅ ៖ ជំរំទី៧ ។ ដល់ក្រោយឆ្នាំនេះហើយទេ បានចូលជំរំតាង៉ុកនឹងក្រោយខាវអ៊ីដាងមុន ។

ធានី ៖ ចុះខាវអ៊ីដាងឆ្នាំប៉ុន្មាន?

ពៅ ៖ ខាវអ៊ីដាង តាំងពីយើងចូលមកនេះដំបូង ។

ធានី ៖ ភាគច្រើនគេអត់មកនៅនេះ គេទៅនៅជំរំ ឬក៏គេនៅជំរំផងនៅនេះផង?

ពៅ ៖ អត់ទេ កាលហ្នឹងមកដល់នេះដំបូងអ្នកណាទៅជំរំទៅ អ្នកណានៅ ។

ធានី ៖ យើងដឹងថានៅខាងនោះមានជំរំហើយ?

ពៅ ៖ បាទ! មាន អង្គការគេកាកបាទគេរៀបចំជំរំ ។

ធានី ៖ កាកបាទអីគេ?

ពៅ ៖ កាលនឹងហៅកាកបាទៗមិនដឹងកាកបាទខាងណា ។

ធានី ៖ គ្រាន់ដឹងថាមានកាកបាទមួយគេនៅខាងជំរំជួយ?

ពៅ ៖ បាទ! អង្គការសហប្រជាជាតិ យើងឃើញទង់សញ្ញា ។

ធានី ៖ ពូចេះភាសាដែរ?

ពៅ ៖ អត់ទេ ។

ធានី ៖ ចុះម៉េចដឹងថាអានឹងទង់អង្គការសហប្រជាជាតិ?

ពៅ ៖ ចេះស្គាល់តៗគ្នា ។

ធានី ៖ ដល់ពេលនៅជំរុំ ពូនៅជំរុំដែរ?

ពៅ ៖ ខ្ញុំអត់ដែលបាននៅទេ ។

ធានី ៖ គ្រាន់ធ្លាប់ឮគេនៅជំរំ?

ពៅ ៖ បាទៗ ។

ធានី ៖ ពូនៅកន្លែងណាវិញទៅ?

ពៅ ៖ យើងនៅតាមអង្គភាព យើងនៅប្រចាំតាមព្រំដែន ។

ធានី ៖ តាមព្រំដែនពីណាទៅណា?

ពៅ ៖ យើងនៅប្រចាំនៅនឹង តែយើងចូលទៅវៃខាងក្នុង ។

ធានី ៖ វៃខាងណា?

ពៅ ៖ វៃនៅតាមកាលនឹងដូចនេះនៅសមរភូមិក្តៅម៉ាជួរនេះមាននៅតាគង់អីនឹង កាលនឹងឃ្លូននៅប្រចាំនឹង ហើយអីចឹងសមរភូមិក្តៅហើយ ។ ហើយឃ្លូនមកដល់ភ្នំនេះ(ភ្នំម៉ាឡៃ) នៅប្រចាំ

មើលទៅឃើញភ្នំ ដាក់គាំភ្លើងធំនៅភ្នំមើលទៅឃើញភ្នំ ហើយយើងនៅអីចឹង។ ប៉ុនកាលនោះ ខាងនោះគេមិនសូវហ៊ានមកយើង ប៉ុនយើងរុកទៅរាល់ថ្ងៃ។

ធានី : ម៉េចអីចឹង?

ពៅ : ចុះយើងទៅវ៉ៃគេនោះ។

ធានី : ទៅវ៉ៃជាមួយគេរហូត?

ពៅ : បាទ! ម៉ាថ្ងៃយើងទៅពាដងចែកជាក្រុម ដូចព្រឹកឡើងកងយើង៣នាក់ទៅវ៉ៃឆ្នូក់ម៉ាប្រាវ ថ្ងៃឡើងពួកគេ៣នាក់ដាក់ទៀតទៅ។ តែគិចកងគេដូចគ្នា ពួស្នូលរហូតមិនសូវឲ្យដាច់ទេ ប៉ុនអត់ច្រើនទេ កម្លាំងវាតិចដែរ។ ដល់អីចឹងយើងវ៉ៃឈ្លប វ៉ៃឆ្នូក់ ទៅលួចដាក់ម៉ាប្រាវៗ ស្ពាយគ្រាប់ឲ្យធ្ងន់ៗទៅដាក់ម៉ាប្រាវ មកវិញទៅ។ ហើយគេទៅដូរទៅ ថ្ងៃល្ងាចគេដូរ។

ធានី : ឆ្ងាស់គ្នារហូត ម៉ាថ្ងៃឆ្ងាស់រហូត?

ពៅ : បាទ!

ធានី : ម៉េចដែរខ្លាចទេ ធ្វើទ័ព?

ពៅ : ដំបូងយើងខ្លាច ប៉ុនដល់យូរៗទៅជាធម្មតា ព្រោះយើងត្រូវតែធ្វើ ត្រូវតែអីចឹងហើយមិនដឹងធ្វើម៉េច បើយើងគេទៅណារួច បើយើងនៅអន្តភាព បើយើងចេញទៅណាក៏ចេញមិនរួច។

ធានី : ម៉េចអីចឹង?

ពៅ : កាលនឹងយើងនៅជាអន្តភាព យើងនៅជាកងអីចឹងហើយយើងចេញអត់រួចទេ។

ធានី : ចុះពូថាអ្នកខ្លះទៅៗ អ្នកខ្លះអត់ទៅៗ?

ពៅ : បាទ! ជាប្រជាជនកាលជំនាន់នឹងក៏វាធូរ កាលមុន។

ធានី : មានប្រជាជនដែរ?

ពៅ : បាទ! ប្រជាជន ហើយទ័ពខ្លះគេបានប្រពន្ធប្តី ក៏គេខ្លះគេទៅៗ ហើយយើងគិតថាបើទៅខ្លាចវាវិលមកវិញមិនបាន។

ធានី : ពូខ្លាចអីចឹង?

ពៅ : បាទ!

ធានី : កាលនឹងពូរៀបគ្រួសារនៅ?

ពៅ : នៅទេ។

ធានី : ណាមួយពូនៅលីវ?

ពៅ ៖ នៅលីវ យើងគិតថាបើសិនណាជាទៅឆ្ងាយចោលស្រុក ខ្លាចវាអត់បានចូលស្រុកវិញ អត់បានជួបជុំម៉ែឪបងប្អូន ចេះគិតអ្នកណាគេគិតផ្សេងក៏គេទៅ អ្នកណាគេគិតរឿងជាតិទឹកដីក៏ទៅណាមិនរួច ។

ធានី ៖ មានប៉ុន្មាននាក់ដែលនៅរៃជាមួយពូ?

ពៅ ៖ កាលនឹងវាច្រើនដែរ ចង់ក្រុងដែរចង់ក្រុងបានកម្លាំងនៅជុំគ្នាច្រើន ចេះរៃតបណ្ដើរៗបានជំនួយគេចេះជួយច្រើនហើយ មានខោអាវមានហូបរបបអីហូបចុកគ្រប់គ្រាន់កាលនឹង ។

ធានី ៖ បរិបូរ?

ពៅ ៖ ហើយកាលនឹងយើងបើករបបប្រចាំហូបចុកអីអត់មានខ្វះអី ប៉ុនអត់មានលុយចាយតាំងពីអំបិល ប្រហុក ប៊ីចេងមកទាំងអស់ ស្អីក៏មិនខ្វះ ។

ធានី ៖ អត់តែលុយចាយ?

ពៅ ៖ ខ្វះលុយចាយ ។

ធានី ៖ កាលនឹងពូរស់នៅក្នុងព្រៃស្នាក់នៅ ហូបចុកយ៉ាងម៉េច?

ពៅ ៖ ពេលដែលយើងច្បាំងនឹង វាធូរដែរ ហូបចុកធូរស្រួល ព្រោះរបបនឹងគេបើកមិនឲ្យមានខ្វះតែគ្រាន់ថាលំបាកយើងថាទៅនឹងមកវាពិបាកយើងដើរ យើងហត់ យើងច្បាំង យើងខ្លាចស្លាប់ ខ្លាចរស់ ។ ប៉ុនគ្រាន់ថារឿងហូបចុកយើងអត់ដែលខ្លាចហត់ បើរឿងហូបចុកយើងអត់ខ្លាចភ័យខ្លាចអត់ ខ្លាចឃ្លានទេ ។

ធានី ៖ ដើរឆ្ងាយៗ?

ពៅ ៖ ឆ្ងាយ ។

ធានី ៖ ដើរពីណាទៅណា?

ពៅ ៖ កាលនឹងដើរសុទ្ធតែដេកផ្លូវ ពីនេះទៅមុខនឹងមាត់វាលនឹង សុទ្ធតែដេកផ្លូវ ។

ធានី ៖ ម៉េចអីចឹង?

ពៅ ៖ ចុះព្រៃ ដើរមិនបានលឿនណា ១ម៉ោងដើរបាន៤គីឡូខំមែនទែន ។

ធានី ៖ ហើយកាលនឹងក្នុងព្រៃនឹងមានអី?

ពៅ ៖ ទេ! មែនទែនមានឃ្លួនស្នាក់តាមផ្លូវនឹង យើងស្នាក់ទៅវិញទៅមក ។

ធានី ៖ មានមីនមានអី?

ពៅ ៖ បាទ! មីននឹងជំនាន់ក្រោយនឹងមាន ។

ធានី ៖ កាលពេលមកដំបូងអត់មានទេ?

ពៅ ៖ មកដំបូងអត់មានមីនទេ ។

ធានី ៖ ហើយម៉េចបានមានមីន?

ពៅ ៖ មីន ដូចយើងនៅនឹងយើងដាក់ការពារកន្លែងយើងនៅ ។

ធានី ៖ យើងនៅបានប៉ុន្មានឆ្នាំ បានចាប់ផ្ដើមដាក់មីន?

ពៅ ៖ មីននឹងមានតាំងពីឆ្នាំ៨០មកហើយ តែគ្រាន់ថាវាតិច ដល់ក្រោយមកទៀត វាចេះដាក់តៗគ្នា ។ ដូចថាកងខ្ញុំនៅប្រចាំនៅនឹងទៅខ្ញុំដាក់ម៉ាខ្សែ២ខ្សែដាក់ការពារ ។ ដល់ពេលកងខ្ញុំផ្លាស់ទៅនៅត្រង់ណាទៀត កងគេមកថ្មីគេត្រូវដាក់ទៀត ។ វាចេះតៗគ្នាទៅ ដល់អីចឹងរកអាប្រភពដើម ចំនុចដែលយើងដាក់នឹង អត់ដឹងទេ គ្រោះថ្នាក់អត់ដឹង ។

ធានី ៖ អ្នកដាក់មិនដាន់ប៉ះមីនខ្លួនឯង?

ពៅ ៖ បាទ! ប៉ះខ្លះ អត់ខ្លះនឹង ។

ធានី ៖ ធ្លាប់មានប៉ះដែរ?

ពៅ ៖ មាន ព្រោះអីព្រៃ ហើយជួនកាលយើងដើរហួសអាខ្សែមីនខ្លួនឯងទៅ មកវិញវាភ្លេចអាត្រង់នឹង ចុះព្រៃមកមិនចំគោលដៅយើងណា ។

ធានី ៖ គេអត់មានធ្វើអីចំណាំ?

ពៅ ៖ វាព្រៃអត់ចំណាំទេ ជួនកាលយើងកាប់គំរុយដែរ ប៉ុនដល់ពេលវង្វេងមិនដឹងណាណៃ ។ ជួនកាលភាវ បើមីនខ្សែស្រួលទេ យ៉ាប់អាមីនដាន់ទេ មីនដាន់វាពិបាក ។

ធានី ៖ មីនខ្សែស្រួលម៉េច?

ពៅ ៖ ស្រួលភាវ កាប់តែកូនរំពាត់ប្រវែងនេះទៅ យើងដើរតឹកៗដើរទាត់ៗទៅប៉ះដឹង ។

ធានី ៖ ប៉ះខ្សែវាមិនផ្ទុះ?

ពៅ ៖ អត់ផ្ទុះទេ ព្រោះកូនឈើរំពាត់តូច យើងគ្រេះចេះរលាស់ទៅដល់យើងប៉ះយើងដឹង ។

ធានី ៖ ចុះមីនពិបាក?

ពៅ ៖ មីនដាន់យើងពិបាកមើលអត់ឃើញ ។

ធានី ៖ យើងធ្វើម៉េចដឹងមានមីនអីខ្លះនៅក្រោមដីនឹង?

ពៅ ៖ វាមែនទែន បើគេថាគេដាក់យើងទៅយើងអត់ដឹង បើថាកងយើងដាក់ យើងដឹងខ្លះ ។

ធានី ៖ ពេលកងពូដាក់មីនអីខ្លះ?

ពៅ ៖ មីនកាលនឹងមីនសំបូរជាងគេ មីនស្គរ និងមីន៦៩ដែលច្រើនជាងគេនឹង ។

ធានី ៖ មីនស្គរម៉េច មីន៦៩ម៉េច?

ពៅ ៖ មីនស្គរវាប៉ុនៗនេះ ហើយមានគំរបកៅស៊ូដូចស្គរមើលទៅ តែវាតូច ។

ធានី ៖ ចុះមីន៦៩?

ពៅ ៖ ៦៩ ប្រវែង១ នេះ ។

ធានី ៖ វែង១?

ពៅ ៖ បាទ! វាធំ១ដែរ ។

ធានី ៖ គេដាក់៦៩សម្រាប់ការពារអី? ហើយមីនស្គរសម្រាប់ការពារអី?

ពៅ ៖ អានឹងមីនតំរូវថ្មើរជើងដូចគ្នាកាលនឹង ។ ប៉ុន៦៩វាលោត វាទាក់ខ្សែហើយវាលោតឡើង អាខ្លះវាកំពស់ត្រឹម-កយើងបានផ្ទុះ អាខ្លះត្រឹមចង្កេះបានផ្ទុះ បើថា១២នាក់ដួលរទាំងអស់ លោតឡើងខ្ពស់ បើអាខ្លះវាផ្ទុះនឹងដីម៉ង ។

ធានី ៖ បើសិនវាអត់លោតទេ វាផ្ទុះនឹងដី?

ពៅ ៖ បាទ! បើវាផ្ទុះនឹងដីក៏វាអំបែងច្រើនដែរ បើមីនស្គរវាបានម្នាក់១ អាមីនស្គរចិនវាអត់ដូច មីនស្គររបស់សូវៀតទេ វាដាច់១ដល់លើ ដាច់ភ្លៅពេលផ្ទុះម្ដង១ តែមីនស្គរចិនដាច់តិច១ តែបើថាពាក់ទ្រនាប់ជើងក្រាស់អានឹងវាដាច់ខ្លាំង ។

ធានី ៖ ម៉េចអីចឹង?

ពៅ ៖ អាទ្រនាប់ជើងនឹងវាជួយ បើទ្រនាប់ជើងស្ដើង១វាអត់សូវដាច់ខ្លាំងទេ ។

ធានី ៖ បើសិនជាយើងដើរស្ដើង១អត់សូវអី បើយើងពាក់ស្បែកជើងរៀងក្រាស់តិច មានបញ្ហាវិញ?

ពៅ ៖ បាទ! អានឹងវាមកដាច់កាន់តែខ្លាំង ទ្រនាប់ជើងវាដាច់អានឹងទៅវាជួយ... ។

ធានី ៖ ចុះមីនខាងវៀតណាមដាក់អានឹងម៉េចវិញ?

ពៅ ៖ អានឹងច្រើនមីនស្នៀតតូច១ ហើយនឹងមីនអាធំ១ប៉ុននេះ ។

ធានី ៖ អានឹងមីនអីគេ?

ពៅ ៖ មីនស្នាច់ ។

ធានី ៖ សម្រាប់ការពារអីគេ?

ពៅ ៖ អានឹងគេការពារថ្មើរជើងដូចគ្នា តែយើងទៅនឹងគេការពារកុំឲ្យយើងទៅដូចគ្នា ការពារបន្ទាយគេនឹង ។

ធានី ៖ កុំឲ្យយើងដើរទៅ?

ពៅ ៖ បាទ! ពេលដែលយើងទៅរកគេនឹង គេដាក់ការពាររបស់គេដែរ ហើយយើងការពាររបស់យើងដែរ ។ ដល់អីចឹង អាគេមកមិនដឹងរបស់យើងដាក់ត្រង់ណា យើងទៅក៏មិនដឹងត្រង់ណា យើងទៅក៏មិនដឹងរបស់គេដាក់ត្រង់ណា ។

ធានី ៖ តែមានប៉ះគ្នា?

ពៅ ៈ ប៉ះមាន ។

ធានី ៈ ដូចពូនិយាយថា៣នាក់ទៅព្រឹក ៣នាក់ទៅថ្ងៃដើរទៅដាន់?

ពៅ ៈ ប៉ះតើ ជួនកាលយើងទៅវ៉ៃគេ ពេលមកវិញ គេស្ទាក់ផ្លូវយើងនេះចុះយើងទៅវ៉ៃរាល់ថ្ងៃ គេលួចមកស្ទាក់វិញ យើងមកវិញអស់គ្រាប់ ជួនកាលប៉ះគ្នាអាពេលនឹង ។

ធានី ៈ គេចាប់បាន?

ពៅ ៈ អត់ទេ វាមិនងាយចាប់បានព្រោះព្រៃ ហើយកម្លាំងយើងតិច អត់ងាយគ្រោះថ្នាក់ទេ អាវ៉ៃអីចឹង ។ បើកម្លាំងគេច្រើន យើងទៅវ៉ៃតែបន្តិចបាញ់តែតិច សឹងនឹងបាញ់ឡើងលើក៏ត្រូវដែរ កម្លាំងគេច្រើន ។ កម្លាំងយើងតិចគេបាញ់ម៉េចក៏មិនងាយត្រូវដែរ ព្រោះកម្លាំងវាតិច ។

ធានី ៈ តែមិនដាន់ប៉ះមីន?

ពៅ ៈ ប៉ះមីនកាលនឹងដីវាទូលាយដែរ វាមិនងាយប៉ះទេ ។ ប៉ុនមីនវាច្រើនដាងថា យើងបាញ់គ្នាយើងច្បាំងគ្នា វាអត់ងាយរបួសងាយត្រូវទេ ខ្មែរក្រហមកាលនឹងដូចថាវាដូចព្រះជួយក៏ថាព្រោះកម្លាំងវាតិច តែបើត្រូវៗនឹងមីន ។ ព្រោះបាញ់គ្នា យើងកម្លាំងតិចអត់ងាយត្រូវយើងបំបែកគ្នាអស់ ដល់កម្លាំងធំមកយើងទល់មុខតែម៉ាក្រុម អានឹងមួយចំហៀង លួចឆ្មក់របួសប៉ុន្មាននាក់គេគិត ។ កាលនោះខ្មែរក្រហមគេមាននយោបាយគេមួយថា ឲ្យវ៉ៃឆ្មក់នឹងឲ្យរបួសម្នាក់២នាក់ ក្នុងម្នាក់ត្រូវសែងគ្នាប៉ុន្មាននាក់ទៅវិញ ដល់កម្លាំងដែលបុកមកវាត្រូវអន់ថយហើយ ។

ធានី ៈ ខស្សាហ៍ទៅឆ្មក់គេច្រើនដង?

ពៅ ៈ និយាយមែនទែន យើងឆ្មក់ជាប្រចាំ បើកម្លាំងទៅឆ្ងាយតិចទៅ វារៀងធូរតិចដែរ មិនសូវបាន ។ បើថានៅតាមព្រំដែនស្ទួរការភ្ជើងអត់ដែលដាច់ទេ បើយើងមិនទៅ ក៏គេទៅដែរ ។

ធានី ៈ ដល់ឆ្នាំប៉ុន្មានបានពូរត់ទៅជំរំខាវអ៊ីដាង?

ពៅ ៈ ឆ្នាំប៉ុន្មាន៨៣ ៨៤ ខ្ញុំចូលជំរុំតាង៉ុកនឹង បានៗប្រពន្ធទៅ ។

ធានី ៈ ជំរំតាង៉ុកនឹងគេហៅជំរំតាង៉ុក?

ពៅ ៈ បាទ! ជំរំតាង៉ុកគេហៅជំរំទី៧ ។ ហើយដល់ខ្ញុំបានប្រពន្ធទៅ ខ្ញុំទៅនៅតាមប្រពន្ធនៅភ្នំឆ័ត្រ

ធានី ៈ ហើយម៉េចទៀត?

ពៅ ៈ ដល់ពេលអ៊ុនតាក់ចូលមក ដល់ត្រូវរូវគ្នាជាមួយខាងសម្តេចរណឫទ្ធិនោះ រដ្ឋាភិបាលខាងក្នុងដល់គេត្រូវរូវគ្នា គេវ៉ៃខ្មែរក្រហមលើភ្នំឆ័ត្រនឹង ក៏ខ្ញុំមកនេះវិញ ។

ធានី ៖ កាលនឹងនៅឆ្នាំ៩០ប៉ុន្មាន?

ពៅ ៖ ៩៣ ។

ធានី ៖ នៅ៩៣ តែគេទៅនោះក៏រត់មកម៉ាខ្សែទាំងអស់គ្នា?

ពៅ ៖ បាទ! ដឹកមកនេះមក តាមដីថៃ ។

ធានី ៖ ដឹកទៅខាងវ៉ៀដាងនឹង?

ពៅ ៖ បាទ! អត់ទេ យើងចេញពីនឹងមកឡានតាមដីថៃមកចូលនេះ ។

ធានី ៖ ម៉េចអីចឹង ម៉េចបានដើរពីនោះមក?

ពៅ ៖ កាលនោះយើងប្រើដីថៃដឹកទ័ព ដឹកគ្រាប់ ។

ធានី ៖ គេអនុញ្ញាតិឲ្យយើងប្រើដែរ?

ពៅ ៖ បាទៗ កាលនោះថៃគេជួយ បើថៃមិនជួយទេ ខ្មែរក្រហមមិនបានរស់ដល់សព្វថ្ងៃទេ ។

ធានី ៖ ពេលទៅរៀបការឆ្នាំប៉ុន្មាន?

ពៅ ៖ ការកាលនោះឆ្នាំប៉ុន្មានទេ ចូលជំរំ ។ ខ្ញុំនៅជំរំបានតិចទេ ពេលការបានប្រពន្ធហើយបានខ្ញុំការបានប្រពន្ធមកនេះ ។ ៨៤ខ្ញុំទៅនោះ ។

ធានី ៖ ការហើយ៨៤ទៅនៅភ្នំឆ័ត្រជាមួយគ្រួសារ?

ពៅ ៖ បាទ!

ធានី ៖ ដល់ពេលប៉ុន្មានបានត្រឡប់មកវិញ?

ពៅ ៖ អ៊ុន គាត់ចូលហើយបានខ្ញុំមកនេះវិញ ត្រឹមវៃសារក្រោយនឹង គេវៃភ្នំឆ័ត្រនឹងបានគេមកនេះ ។

ធានី ៖ ភ្នំឆ័ត្រហើយ អ្នកណា អ្នកដឹកនាំមកនេះវិញ?

ពៅ ៖ បាទ! កាលនឹងកម្លាំងដែលនៅនឹង វាអត់មានដីនៅ ដល់អីចឹងវាត្រូវដឹកមកនេះវិញទាំងអស់

ធានី ៖ មិនមែនមេបញ្ជាការគេទាក់ទងមកនេះ?

ពៅ ៖ អត់ទេ មេគេឲ្យមកនៅ គ្រាន់ថាបើយើងនៅនោះគេឲ្យនៅនោះ ប្រជាជន ឬប្រពន្ធទ័ពនៅអត់កើត ។

ធានី ៖ ម៉េចអីចឹង?

ពៅ ៖ វានៅដូចថាដីវាចង្អៀតពេក ។

ធានី ៖ តូចពេក?

ពៅ ៖ បាទ! តូចពេក គេត្រូវឲ្យប្រពន្ធកងទ័ពមកនៅនេះទាំងអស់ ហើយទ័ពនៅនឹង ។

ធានី ៖ នៅវៃទៀត?

ពៅ ៖ បាទ! នៅវ៉ៃទៀត ។

ធានី ៖ ម៉េចទៀតទៅពូ ពេលវ៉ៃពេលអី?

ពៅ ៖ ពេលវ៉ៃវាមែនទែនជាប្រពៃណីកន្ទែព ជាធម្មតាទៅជាទម្លាប់ធម្មតា ។

ធានី ៖ ពូនិយាយថា ពេលមកដល់នេះមកដល់ឆ្នាំប៉ុន្មាន ៩៣?

ពៅ ៖ ៩០ប៉ុន្មាន ។

ធានី ៖ ពូថាអ៊ុន គាត់មក ចេញពីភ្នំឆ័ត្រមក?

ពៅ ៖ អ៊ុន គាត់នឹងខ្ញុំនៅនោះខ្ញុំបានដឹកកម្លាំងដឹកអីគេទៅបោះឆ្នោតនៅថ្មពួកនឹង ។ ដល់ពេលគេបោះឆ្នោតអីហើយម៉ាសារទៀត បានខ្ញុំរត់មកនេះ យូរដែរអ៊ុន គាត់មក ។

ធានី ៖ រត់មកនេះឆ្នាំប៉ុន្មាន?

ពៅ ៖ ធ្វើដូវកាលនឹងមើល ធ្វើដូវជាមួយអ៊ុនគាត់ បានឆ្ងាយដែរនឹង ។

ធានី ៖ មកដល់នេះបានបោះឆ្នោតនឹងគេទេ?

ពៅ ៖ មានតើ ។

ធានី ៖ បោះឆ្នោតម៉េច?

ពៅ ៖ ហ៎! អត់ទេ បោះនៅនោះទេ មកដល់នេះបោះយើងផ្តាច់ខ្លួនហើយទេ ប៉ុននៅនោះកាលនោះអ៊ុនគាត់ យើងបានបោះដែរ ។ កាលនឹងយើងខ្មែរក្រហមគេបោះឲ្យរណរិទ្ធ ព្រោះសម្តេចរណរិទ្ធិថា បើសម្តេចរណរិទ្ធិជាប់ឆ្នោត គេនឹងជួយខ្មែរក្រហម កាលនឹងខ្មែរក្រហមអត់ចូល ។ ដល់អីចឹងយើងមានឡាន មានសម្ភារៈនឹងទៅដឹកប្រជាជន ។

ធានី ៖ ដឹកប្រជាជនពីណាមក?

ពៅ ៖ ដឹកប្រជាជនតាមភូមិអាស្រុកថ្មពួកនឹង ដឹកមក ។

ធានី ៖ ប្រជាជនដែលខ្មែរក្រហម?

ពៅ ៖ បាទ! ប្រជាជនអតីតនិយាយមែនទែន វាគាំទ្រមិនមែនតែខ្មែរក្រហម គាំទ្រច្រើនគណបក្សមានគណបក្សតាសឹន សាន មានគណបក្សរណរិទ្ធិ ដឹងជុំគ្នា ឲ្យតែអ្នកដែលបោះឆ្នោតត្រូវដឹកយកមកតាមភូមិ ។

ធានី ៖ ដល់ពេលគាត់ជាប់ឆ្នោតម៉េចទៀត?

ពៅ ៖ គាត់ជាប់ឆ្នោតត្រូវជាមួយរដ្ឋាភិបាល វ៉ៃខ្មែរក្រហមដដែល ។

ធានី ៖ ដល់ពេលអីចឹងពូមានអារម្មណ៍យ៉ាងម៉េចទៅ?

ពៅ : មានអារម្មណ៍ថា បើមែនទែនកាលនឹងនាំគ្នាចេះថាមនុស្សក្រពើ ព្រោះអីអន្ដរទឹកត្រីអីភាគច្រើនបានពីខ្មែរក្រហម គ្រាប់អីនឹង អត់ឃ្លានមានស៊ីអីរត់មករកខ្មែរក្រហមដែរ ។ ដល់គេបានទាក់ទងជាមួយរដ្ឋាភិបាល គេមកវ៉ៃយើងវិញ ។

ធានី : ខឹងតែម្ដង?

ពៅ : បាទ! ខឹងដែរនឹង ។

ធានី : ម៉េចបានពូដឹងរឿងនឹង?

ពៅ : ចុះយើងនៅនឹងជាប់ទាំងអស់គ្នា ព្រោះកន្លែងខ្ញុំនៅនឹង ឡានពួកអាដែងគេនឹងមកដឹកគ្រាប់រាល់ថ្ងៃនឹងយកគ្រាប់ពីខ្មែរក្រហមទៅ ។

ធានី : ពូនៅឃ្លាំង?

ពៅ : បាទ! ខ្ញុំនៅជុំវិញឃ្លាំង ។

ធានី : ឃ្លាំងនៅម៉ាឡៃ ឬនៅភ្នំឆ័ត្រ?

ពៅ : នៅភ្នំឆ័ត្រ ។

ធានី : ដល់ពេលមកដល់ម៉ាឡៃបានពូថាធ្វើកងពិសេសម៉េចនោះ?

ពៅ : អានឹងខ្ញុំនៅមុននឹងទៀតកងពិសេស ដែលខ្ញុំទៅនោះទៀត ។

ធានី : ដែលថាពូមិនទាន់មានគ្រួសារទេ ខស្សាហ៍ជូនភ្ញៀវជូនអី នៅកងជីវីនឹង?

ពៅ : បាទ! ហ្នឹងខ្លួនមួយ ។

ធានី : ដល់មានគ្រួសារបានទៅនោះ?

ពៅ : បានទៅនោះ ។

ធានី : បានត្រឡប់មកវិញនៅឆ្នាំប៉ុន្មាន?

ពៅ : មកដល់នឹងខ្ញុំដូចភ្លេចដែរ មកនៅបានប៉ុន្មានផ្ដាច់ខ្លួន ខ្ញុំអត់សូវបានចាំរឿងនឹង ។

ធានី : ប៉ុន្តែពូមកនៅនេះមកធ្វើអីគេ?

ពៅ : បាទ! មកនៅនេះខ្ញុំឈប់ធ្វើ មានឈ្មោះកងទ័ពដែរ ប៉ុនខ្ញុំខាងបើកបរទេ ។

ធានី : បើកបរអីគេ?

ពៅ : បើកបរឡានដឹកដីធ្វើផ្លូវធ្វើអីនឹង ។

ធានី : កាលនឹងធ្វើផ្លូវខ្លួនឯង?

ពៅ : បាទ! ធ្វើផ្លូវដឹកចាក់ ដូចថាផ្លូវណាដាច់ៗខូចៗយើងចេះជួសជុលទៅឲ្យទ័ពគេចល័តខាងប៉ៃលិនមកឲ្យគេមកជួយនៅនេះ ហើយដឹកពីនេះទៅជួយនៅនោះអី ចល័តស្រួលចុះឡើង ។ អីចឹងយើងជួយសម្រួលធ្វើផ្លូវនឹង ចេញពីកងទ័ព ។ ដូចមិនចេញទេ គ្រាន់ឈ្មោះនៅអន្ក

ភាពកងទ័ព ប៉ុនយើងខាងបើកបរវិញ ។

ធានី ៖ ហើយម៉េចទៀតទៅ?

ពៅ ៖ ដល់ក្រោយមកផ្តាច់ខ្លួននឹង យើងធ្វើផ្លូវចេះធ្វើទៅ ត្រង់ណាមេឲ្យធ្វើ យើងចេះធ្វើ ។

ធានី ៖ បន្ទាប់ពីពូធ្វើផ្លូវដល់ឆ្នាំប៉ុន្មានបានគេផ្តាច់ខ្លួន?

ពៅ ៖ ផ្តាច់ខ្លួនឆ្នាំប៉ុន្មាន ដល់ផ្តាច់ទើបឈប់នៅអង្គភាព យើងនៅតែបើកឡានដួសដុលផ្លូវនឹងដដែល ទល់សព្វថ្ងៃនឹងនៅតែឡានរហូត ។

ធានី ៖ ធ្វើឡានដឹកដីទៅ?

ពៅ ៖ បាទ!

ធានី ៖ ធ្វើខ្លួនឯង ប្រធានខ្លួនឯង?

ពៅ ៖ កាលមុនយើងដឹកសម្រាប់អង្គភាព សម្រាប់អ្នកស្រុកម៉ាខ្លៃ ប្រចាំកងពលនៅនេះ យើងចេះធ្វើទៅ ។ ដល់ក្រោយមក គេផ្តាច់ខ្លួនទៅឡាននឹងយើងនៅកាន់កាប់រហូត យើងនៅបើកបរ ប៉ុនគ្រាន់ថាយើងស៊ីភាគរយ ដល់អីចឹងក្រោយមកឡាននឹងគេលក់អស់ទៅ ឡានរបស់ក្របខ័ណ្ឌរបស់ខ្មែរក្រហម ឈុតថ្មី ក្រុមគេទិញថ្មីមកទៀត ។

ធានី ៖ ក្រុមហ៊ុនអីគេ?

ពៅ ៖ ក្រោយនេះ អ៊ំ យិន ក្រុមហ៊ុនចៅហ្វាយស្រុកក្រោយ ។

ធានី ៖ ពូជាអ្នកបើកឡានឲ្យគេទេ?

ពៅ ៖ បាទៗ ។

ធានី ៖ មានចំការមានស្រែអីទេ?

ពៅ ៖ ស្រែចំការខ្ញុំអត់ទេ កាលនឹងខ្ញុំបាក់ជើង ដល់យើងទៅចាប់ចំការសារក្រោយដែលយើងផ្តាច់ខ្លួនហើយនេះ ចាប់បានតែយើងអត់មានលទ្ធភាពទៅធ្វើ ព្រោះអីយើងដើរអត់រួច ។

ធានី ៖ គេអត់ឲ្យយើងវិញ?

ពៅ ៖ អត់ទេ គេមិនអត់ឲ្យទេ ប៉ុនយើងអត់មានលទ្ធភាពទៅធ្វើ ដល់យូរៗគេយកអស់ទៅ ។

ធានី ៖ ក្រែងរបស់អ្នកណា របស់អ្នកនឹង គេអត់យក?

ពៅ ៖ អត់ទេ កាលនឹងអ្នកណាកាប់បានប៉ុន្មានយកប៉ុននឹង ។

ធានី ៖ ទោះយើងកាប់បានប៉ុន្មាន បើយើងអត់ទៅធ្វើ គេយកដដែល?

ពៅ ៖ បាទ! គេធ្វើគេយកហើយ ។ ហើយអីចឹងខ្ញុំទៅទិញដីម៉ក់ហឹន ហួសខ្វាងាប់តិចទិញដីស្រែបាន២-៣ហាត់(ហិចតា)ដែរ ។ ប៉ុនវាស្មើរទឹកស្មើរគោក អត់ធ្វើអីកើតប៉ុន្មានឆ្នាំ ។

ធានី ៖ ពូដែលធ្លាប់ជួយអ្នកដទៃនៅសម័យខ្មែរក្រហម?

ពៅ ៖ កាលនោះខ្ញុំធ្លាប់នៅពេទ្យ ខ្ញុំធ្លាប់បានជួយសង្គ្រោះគេច្រើន ប៉ុន្តែខ្ញុំចាប់មុខរបរអាជីពពេទ្យនឹង វាទៅអត់រួច យើងអត់ចេះអក្សរ ។

ធានី ៖ ឆ្នាំប៉ុន្មានដែរ ពូចាប់អាជីពពេទ្យ?

ពៅ ៖ កាលនៅភ្នំឆ័ត្រនឹងខ្ញុំនៅពេទ្យរហូត ៨៣ ៨៤ ខ្ញុំនៅរហូតទល់អ៊ុន គាត់ចូលបានខ្ញុំឈប់បានខ្ញុំនៅបើកបរវិញ ។ យើងទៅវះកាត់អីជាមួយគេបាន បាននឹងយើងរៀនបឋម រៀនដាក់ស្ដែង គ្រាន់យើងមិនបានទៅប្រើថ្នាំ យើងទៅវះកាត់ជាមួយគេ ។

ធានី ៖ ជួយអ្នកណាគេ?

ពៅ ៖ ជួយកងទ័ពបានច្រើនដែរ ។

ធានី ៖ ស្គាល់ឈ្មោះពួកគាត់ទេ?

ពៅ ៖ ច្រើនពេកភ្លេចអស់ហើយ ។

ធានី ៖ គាត់ដែលធ្លាប់មកលេង?

ពៅ ៖ បាទ! នេះនៅ៩៣ពួកគាសោរអីកំបុតជើង គៀបប៉ូលីសនេះខ្ញុំបានខ្វះភ្នែកគាត់ កំបុតដៃមួយចំហៀង ខ្វះភ្នែកមួយ ។

ធានី ៖ ម៉េចអីចឹង?

ពៅ ៖ កាលនឹងគាត់ទៅវៃនៅណា គោកម៉ន របួសហើយវៃណាទេកាលនឹង ។ ដល់ហើយរបួសមកដេកពេទ្យនៅកន្លែងខ្ញុំ ។

ធានី ៖ របួសភ្នែក របួសជើង?

ពៅ ៖ បាទ! គាត់ត្រូវកាត់ដៃមួយ ហើយខ្វះភ្នែកមួយ ។

ធានី ៖ ធ្វើម៉េចទៅខ្វះភ្នែកនឹង?

ពៅ ៖ មានអីយើងនៅក្នុងព្រៃ វាមិនបានហូបចុកគ្រប់គ្រាន់កាលនឹងយើងនៅក្នុងព្រៃ ហើយកាលពេលវៃគ្នានៅខែប្រាំងនឹង យើងមានទៅរើកន្លែងរត់រហូត ។ អីចឹងមើលកន្លែងណាក្រោមដើមឈើណាម្ហូប់បន្តិចយើងក្រាលក្តៅស៊ូ វះកាត់ទៅតាមដំណើរយើងទៅ ហើយធ្វើម៉េចទឹកក៏ខ្វះអីក៏ខ្វះ ។

ធានី ៖ ពូដឹងសន្តិភាពពេលណា?

ពៅ ៖ ដែលសន្តិភាពដែលយើងត្រូវគ្នានេះ ។ យើងផ្ដាច់ខ្លួននឹង ។

ធានី ៖ ឆ្នាំប៉ុន្មាន?

ពៅ ៖ ឆ្នាំណាទេ រឿងឆ្នាំខ្ញុំអត់សូវច្បាស់ មិនដែលយកចិត្តទុកដាក់ គ្រាន់សួរឈ្មោះកូនខ្ញុំកើតឆ្នាំអី ក៏ខ្ញុំអត់ដឹងរាល់ថ្ងៃ បើយើងដើរនោះ ។ ដើរចុះឡើងវាមិនបានយកចិត្តទុកដាក់ ។

ធានី ៖ ពូដែលឮពាក្យសារតាំង?

ពៅ ៖ សារតាំងខ្ញុំឮយូរហើយ ។

ធានី ៖ សារតាំងនឹងអីគេ?

ពៅ ៖ សារតាំងខ្ញុំឮថាកាលនឹងសម្តេចសីហនុមកទទួលសារតាំងនៅនឹង នៅឈ្មោះជាប់នៅនឹង ។

ធានី ៖ សារតាំងជាស្អីទៅពូដឹងទេ?

ពៅ ៖ កន្លែងទទួលសម្តេច ។ ពាក្យសារតាំងខ្ញុំមិនសូវច្បាស់ដែរ ។

ធានី ៖ សម្តេចមកធ្វើអី?

ពៅ ៖ មកទទួលសារតាំងនឹងម៉ង ។

ធានី ៖ មកឆ្នាំណា?

ពៅ ៖ ឆ្នាំណាទេ ខ្ញុំអត់សូវច្បាស់ទេ រឿងឆ្នាំ ។

ធានី ៖ ពេលនឹងសន្តិភាព ឬនៅ?

ពៅ ៖ នៅទេ ។

ធានី ៖ ហើយគាត់មកទទួលសារតាំងនឹងមុន?

ពៅ ៖ បាទ! លោកមក២ដង មកនេះ ។

ធានី ៖ គាត់មកធ្វើអីគេ២ដង?

ពៅ ៖ ខ្ញុំមិនសូវដឹងជ្រៅដែររឿងនឹង ។

ធានី ៖ ប៉ុន្តែគ្រាន់ដឹងថាមក?

ពៅ ៖ មក ។

ធានី ៖ មកនៅកន្លែងណា?

ពៅ ៖ មកនៅស្នាក់នៅសារតាំងនឹងម៉ង ។

ធានី ៖ គាត់មកស្នាក់នៅសារតាំងនឹង ស្នាក់នៅធ្វើអីពូដឹងទេ?

ពៅ ៖ រឿងអ្នកធំៗ ខ្ញុំអត់សូវយល់ដែរ ។

ធានី ៖ គាត់ស្នាក់នៅម៉ាថ្ងៃ ឬគាត់មកមួយភ្លែតគាត់ទៅវិញ?

ពៅ ៖ នៅម៉ាថ្ងៃៗ ។

ធានី ៖ នៅវិញល្ងាច?

ពៅ ៖ គាត់ចូលពេលព្រឹក ល្ងាចវិលវិញ ។

ធានី ៖ ចិត្តពូយល់ថាម៉េចដែរចំពោះការផ្សះផ្សា?

ពៅ : បាទ! អានឹងវាបើមែនទែនទៅកុំបានការផ្សះផ្សាយើងមិនដឹងទៅជាស្អី ឈ្លោះគ្នាវ៉ៃគ្នាមិនដឹងប៉ុន្មានឆ្នាំទៅទៀតនឹងចប់ ។ បានផ្សះផ្សាគ្នា ត្រូវគ្នាវាល្អហើយ ។

ធានី : ពូគិតថាការផ្សះផ្សានៅជិត ឬនៅឆ្ងាយពីគ្នាល្អជាង?

ពៅ : មែនទែនទៅ វានៅជិតក៏ល្អ នៅឆ្ងាយក៏ល្អ បើគិតមែនទែនទៅឲ្យតែបានថាយើងនិយាយគ្នា យើងផ្សះផ្សាគ្នាឲ្យស្គាល់ចិត្តគំនិតគ្នាទៅ ឲ្យយល់គ្នាទៅវិញទៅមកទៅវាមិនថាជិតថាឆ្ងាយដូចល្អទាំងអស់ ឲ្យបានថាយល់គ្នាកុំឲ្យឈ្លោះប្រកែកគ្នាទៅថ្ងៃមុខ ថ្ងៃក្រោយ ។

ធានី : ចិត្តពូគិតថាមួយណាល្អជាង?

ពៅ : បើនិយាយមែនទែនជិតវាល្អហើយ ព្រោះអីប្រយោលដូចថាអត់ដឹងចិត្តគ្នាជ្រៅ បើថាជិតកាន់តែល្អ វាបានស្គាល់ចិត្តគំនិតគ្នាទៅយើងស្រួលដឹងចិត្តគំនិត ។

ធានី : អ៊ំវ៉ាន់គ្រប់គ្រងតាំងពីឆ្នាំណាដល់ឆ្នាំណា?

ពៅ : តាំងពីយើងសម័យ៣ឆ្នាំមកដល់នេះគាត់រហូត ។

ធានី : ៣ឆ្នាំ រហូតមកដល់ឥឡូវក៏គាត់គ្រប់គ្រងដែរ?

ពៅ : បាទ!

ធានី : ឥឡូវអ៊ំវ៉ាន់គាត់គ្រប់គ្រងដដែល?

ពៅ : បាទ! ដល់ក្រោយមកគាត់នៅតែរហូត ប៉ុនគាត់អត់ត្រូវគ្នាជាមួយអាពតក៏គាត់ទៅសម្រាកនៅដីថៃ ។

ធានី : អត់ត្រូវគ្នាឆ្នាំប៉ុន្មាន ពូដែរចាំ?

ពៅ : ខ្ញុំអត់ចាំទេ អ៊ំយិនគាត់ច្បាស់ គាត់នៅជាមួយរហូត ។

ធានី : គាត់នៅជាមួយអ្នកណាគេ?

ពៅ : គាត់នៅជាមួយអ៊ំវ៉ាន់រហូត បម្រើភ្ញៀវចេញចូលលើគាត់ ។

ធានី : អ៊ំអីគេពូថា?

ពៅ : អ៊ំយិន ។

ធានី : ផ្ទះគាត់នៅម្តុំណា?

ពៅ : នេះត្រង់នេះ ។

ធានី : ជាប់ផ្ទះមីងបូដែរ?

ពៅ : ខាងនេះ ផ្ទះមានដើមអំពិលនេះ ។

ធានី : នៅម្តុំយើងនេះ?

ពៅ : បាទ! បត់កែងទៅវិលផ្ទះ២ នៅខាងឆ្វេងដៃ ។

ធានី ៖ ផ្ទះលាបថ្នាំសនឹង?

ពៅ ៖ នឹងហើយមានឡានពីមុខ២-៣ ។

ធានី ៖ ផ្ទះថ្មីឡើងខ្ពស់លាបថ្នាំសៗ?

ពៅ ៖ បាទៗ មានទ្វារដែក ។

ធានី ៖ មានរបង ឬអត់របង?

ពៅ ៖ ផ្ទះនឹងមានដាំផ្កាពីមុខ ហើយមានអំពិលមួយដើម ខាងក្នុងមានឡានបញ្ឈរពីមុខ២-៣ ។

ធានី ៖ មានរបង?

ពៅ ៖ បាទ! ខាងមុខអត់មានទេ ផ្ទះថ្មីរបងគេខាងនោះ ។

ធានី ៖ ផ្ទះគាត់លាបថ្នាំពណ៌ស?

ពៅ ៖ បាទ!

ធានី ៖ គាត់ទើបនឹងធ្វើផ្ទះនឹងទេ ឬក៏អី?

ពៅ ៖ អត់ទេ គាត់ធ្វើយូរហើយ គាត់គ្រាន់គាត់កែម៉ាសារ ព្រោះផ្ទះនឹងធ្វើកាលពេលចេញពីដីថៃមកនៅនឹងគាត់ធ្វើម៉ាសារ ផ្ទះនឹងវាទាបពេករួសចេញធ្វើថ្មីអានេះ ។

ធានី ៖ តែម៉ូតដដែល?

ពៅ ៖ បាទ! ខុសមុនតិច ។

ធានី ៖ គាត់ឈ្មោះអី?

ពៅ ៖ អូ! អ៊ំយិន ។

ធានី ៖ អីគេយិន?

ពៅ ៖ ជីតាគាត់ឈ្មោះអីទេ សោម យិន ។

ធានី ៖ គាត់នឹងនៅក្បែរអ៊ំវ៉ាន់?

ពៅ ៖ គាត់ដឹងរឿងច្រើន ព្រោះគាត់នៅជាប់ គាត់អ្នកគ្រប់គ្រង គាត់អ្នកខាងសេដ្ឋកិច្ច បើភស្តុភារ ។

ធានី ៖ គាត់អ្នកក្តាប់ភស្តុភារទាំងអស់?

ពៅ ៖ បាទ!

ធានី ៖ ប្រជាជនចង់ហូបចង់អីលើគាត់?

ពៅ ៖ បាទ! បើករបបហូបចុកអីគ្រាប់ចេញចូលត្រង់ណាលើគាត់ រូបថតអីគាត់សល់ច្រើនមានភ្ញៀវចេញចូលពីណាៗ ។

ធានី ៖ គាត់នៅសល់រូបថតចាស់ៗច្រើន?

ពៅ ៖ កាលពួកកាសែតមកធ្វើសន្និសិទកាសែត គាត់ឲ្យគេច្រើនមិនដឹងនៅប៉ុន្មានទេ ។

ធានី ៖ ធ្លាប់មានធ្វើសន្និសិទកាសែតនៅកន្លែងយើងដែរ?

ពៅ ៖ បាទ!

ធានី ៖ ពីអន្តរាល់?

ពៅ ៖ កាលយើងផ្ដាច់ខ្លួនហើយនឹង ។

ធានី ៖ ផ្ដាច់ខ្លួនហើយភ្លាម មានសន្និសិទកាសែតភ្លាម?

ពៅ ៖ បាទៗ ហើយមុននឹងភ្ញៀវចូលមកមុនថ្ងៃណាៗ រូបថតគាត់មានទាំងអស់កាល ឃើញឲ្យពួកកាសែតច្រើនណាស់ ។ ឥឡូវនឹងគាត់នៅតាមដានពត៌មានច្រើន បើកមើលInternateរបស់គាត់ ចាំរបស់គាត់ ។

ធានី ៖ គាត់មានInternate?

ពៅ ៖ បាទៗ ។

ធានី ៖ គាត់ចេះភាសាបរទេសហើយ?

ពៅ ៖ ភាសាគាត់មិនសូវចេះ និយាយថៃគាត់ស្ដាប់បាន ។

ធានី ៖ គាត់ជូនភ្ញៀវចុះឡើង?

ពៅ ៖ អត់ទេ គាត់គ្រាន់អ្នកទទួលជួយកិច្ចការនៅក្នុងនឹង គាត់អ្នកគ្រប់គ្រងនៅក្នុងនឹងដែរ ។

ធានី ៖ គាត់អ្នកខាងគ្រប់គ្រងសម្ភារៈអីនឹង?

ពៅ ៖ បាទៗ ។

ធានី ៖ តែពូអ្នកជូនភ្ញៀវវិញ?

ពៅ ៖ បាទ! និយាយមែនទែនវាតូចតាច ។

ធានី ៖ ហើយមកដល់រាល់ថ្ងៃពួកគាត់ធ្វើអី?

ពៅ ៖ ឥឡូវគាត់ ក្រុមហ៊ុនគាត់... ក្រុមហ៊ុនរកស៊ីនៅស្រុកយើងនេះ គាត់មានក្រុមហ៊ុនមួយបើកស៊ីឡូ ទិញពោតទិញដំឡូងរាល់ថ្ងៃ ។

ធានី ៖ ទិញពោត ដំឡូងយកទៅថៃ?

ពៅ ៖ បាទ! គាត់ចេះថៃ គាត់ទំនាក់ទំនងជាមួយថៃបានល្អ ។

ធានី ៖ គាត់រៀនគ្រាន់បើដែរ?

ពៅ ៖ គ្រាន់បើដែរ ប៉ុនគាត់ចូលចិត្តនិយាយលេង ស្រទាប់លើស្រទាប់ក្រោមគាត់ចូលទៅគ្រង់ណាក៏ចុះដែល គាត់មិនប្រកាន់ ។

ធានី ៖ គាត់ដើរច្រើន ដឹងច្រើន?

ពៅ :	បាទៗ គាត់មនុស្សមិនរើសអើង ។

ធានី :	ពូមាននៅសល់រូបថតចាស់ៗពីមុនក៏ដោយដែលពូគិតថារូបថតចាស់ៗ ?

ពៅ :	អត់ទេ រូបថតនៅសល់តែរបស់ខ្លួនឯង ។

ធានី :	អានឹងរូបថតអីគេ?

ពៅ :	រូបថតទាហានសម័យនឹង

ធានី :	ពីពេលណាមក?

ពៅ :	រូបថតនៅនេះឯង ថត៨៣ ។

ធានី :	ថតនៅណាវិញ?

ពៅ :	នេះខ្ញុំថតនៅភ្នំឆ័ត្រ ។

ធានី :	ថតជាមួយអ្នកណាគេ?

ពៅ :	ជាមួយបងប្អូនសព្វថ្ងៃគាត់នៅអន្លង់វែង ។

ធានី :	គាត់ឈ្មោះអីគេ?

ពៅ :	គាត់ឈ្មោះ ផន គាត់បានបួសដែរ ដល់អីចឹងហៅគាត់តែលោកបងផន ។ ការថតក្មេងជាង នឹងវាអស់ ថតរួមគ្នាជាកងៗ បើយើងរើកន្លែងរត់ចុះឡើង វាអស់ ។

ធានី :	ចុះម៉េចពូទុករូបមួយនេះ?

ពៅ :	អានេះទើបថតដែលយើងក្រោយ ហើយបេះនៅ ទុកគ្រាន់ឲ្យកូនមើល ។ កាលសម័យខ្មែរក្រហមក៏គេថតឲ្យដែរ តែគេថតជាទស្សនាវដ្ដីអី ។

ធានី :	ពូមានទុកដល់ឥឡូវ?

ពៅ :	អត់ទេ កាលរើផ្ទះដុតចោលអស់រញ៉េរញ៉ៃពេក ចុះទុកទៅកណ្ដុរវាកាត់ខ្លះ ដាមទឹកខ្លះទុកធ្វើអីច្រើនពេក ។

ធានី :	ចុះម៉េចទុកមួយនេះ?

ពៅ :	អានេះវានៅអត់នេះ ខ្ញុំទើបរើកាលណាប៉ុន្មានឆ្នាំមុនខ្ញុំរើឃើញវាអស់ វាមានតែអានឹងក៏ខ្ញុំឲ្យគេទៅៗ ។

ធានី :	ប្រហែលជាឆ្នាំប៉ុន្មានរូបថតនឹង?

ពៅ :	បើមិន៩២ ៩៣ ។

ធានី :	ហើយបានកាំម៉ារ៉ាពីណាមក?

ពៅ :	កាំម៉ារ៉ាថៃ កាលនឹងគេមកថតយកលុយ កាលនឹងយើងនៅតាមព្រំដែនថៃដើរថតឲ្យ ។

ធានី :	ហើយកាលនឹងថតក្នុងពិធីអីគេ?

ពៅ ៖ អានេះខ្ញុំរៀបបែកពីគាត់ ខ្ញុំឡើងឡានទៅដងរែកទៀត គេឲ្យទៅចុះនៅដងរែក ចុះភ្នំគ្រាំត្រង់ពិបាកចុះ យើងត្រូវចុះនៅក្នុង ។ គាត់នៅប្រចាំពេទ្យ ខ្ញុំនៅពេទ្យកង ។

ធានី ៖ ពូធ្វើពេទ្យដែរកាលពេលនឹង?

ពៅ ៖ បាទ! កម្លាំងកងខ្ញុំត្រូវចុះ ខ្ញុំត្រូវបែកពីគាត់ គាត់ឲ្យគេថតម៉ាប៉ុស្តិ៍ ។

ធានី ៖ ថតឲ្យមួយប៉ុស្តិ៍ គាត់អ្នកទុក ហើយពូអ្នកទុក?

ពៅ ៖ គាត់ឲ្យខ្ញុំ អានេះគាត់ទើបយកមកឲ្យកាលក្រោយហើយទេ ព្រោះថតហើយខ្ញុំឡើងទៅទាំងយប់ ។ កាលនឹងខ្ញុំដុតចោលច្រើនហើយ ព្រោះអត្តសញ្ញាណប័ត្ររបស់ទាហានយួន ខ្ញុំប្រមូលពីឃ្លាំងមកបានមិនចេះតិចទេ ។

ធានី ៖ មានទៀត?

ពៅ ៖ មានគេចាប់យួនបាន គេដាក់កេះទៅខ្ញុំយកមកទុក ដល់ខ្ញុំរើផ្ទះធ្វើផ្ទះដុតចោល ។ លុយខ្មែរក្រហម ។ មានតែអឺយិនទេ ដែលគាត់នៅច្រើន តាំងពីទស្សនាវដ្តីឃើញគាត់នៅច្រើន ។

ធានី ៖ មានរូបពូទេ?

ពៅ ៖ អត់ ។

ធានី ៖ គេថតរូបពូនៅក្នុងនឹង?

ពៅ ៖ អានឹងវាច្រើនរញ៉េរញ៉ៃមិនដឹងស្អីៗ ក្រដាស២០សន្លឹករហែកត្រង់នេះមិនយក ។ ក្នុងទស្សនាវដ្តីអារូបនឹងក៏មានដែរ ក្នុងទស្សនាវដ្តីខ្មែរក្រហម ។ កាលនឹងថតនៅណា នៅសៀមរាប ។ នៅក្នុងទស្សនាវដ្តីនឹងគេដាក់ តែវារៀងយូរពេកហើយ គេចោលខ្ទេចខ្ទីអស់ ។ ម៉ាកេះប៉ុននេះ មិនដឹងស្អីខ្លះ ដុតដោយទាំងប្រវត្តិដែលយើងចូលកងទ័ពពីថ្ងៃណាៗដោយទាំងអស់ ។

ធានី ៖ មានគេធ្វើប្រវត្តិរូប?

ពៅ ៖ បាទ! គេធ្វើការពេលខ្ញុំកាត់វិសាយវគ្គមួយ ។

ធានី ៖ កាត់វិសាយឆ្នាំប៉ុន្មាន?

ពៅ ៖ ឆ្នាំណាទេ កាលយើងកាត់វគ្គមួយចូលមណ្ឌល ខ្ញុំភ្លេចហើយ ខ្ញុំអស់សូវចាំឆ្នាំ ។

ធានី ៖ ប្រហែលពីនឹងមកដល់ឥឡូវប៉ុន្មានឆ្នាំ?

ពៅ ៖ ប៉ុន្មានឆ្នាំ៤-៥ឆ្នាំ បើខ្ញុំកាត់វគ្គមួយកាត់មុនគេ ហើយគេកាត់ក្រោយៗនេះ គេអត់បានចូលមណ្ឌលទេ គេបើកប្រាក់យកតែម្តង ។ តែចូលមណ្ឌលវាបានជាសម្ភារៈវិញ មានរបស់របរចានឆ្នាំងវិញ តែបើក្រោយនេះគេបើកប្រាក់យកៗ ។

ធានី ៖ ពូឆ្លងកាត់២-៣ជំនាន់ច្រើនជំនាន់?

ពៅ ៖ បើមែនទែនប្រវត្តិខ្ញុំជាប់គុកក៏មាននៅខ្មែរក្រហម ។ កាលនឹងខ្ញុំនៅ៣២ គេថាខ្ញុំចង់រត់មកនៅម៉ាឡៃនឹង គេនៅកងនឹងគេរត់៤នាក់ ខ្ញុំអត់រត់ទេព្រោះខ្ញុំអត់ដឹងអីទេ ។ ដល់ហើយគេសង្ស័យយើង ដល់អីចឹងគេយកយើងដាក់គុកបានជិត៣ខែដែរ កាលនឹង២ខែប៉ុន្មានថ្ងៃ ។ បានយួនចូលមកតាមព្រំដែន វាលែងទៅ គេឲ្យយើងទៅច្បាំងជាមួយគេ បានខ្ញុំមកនេះ ។

ធានី ៖ នៅ៣២ នៅកន្លែងណា?

ពៅ ៖ នៅកងពិសេស តាកន ។

ធានី ៖ កងអីគេ?

ពៅ ៖ កងទ័ពពិសេស ។

ធានី ៖ របស់អ្នកណាគេ?

ពៅ ៖ របស់តាកន ។

ធានី ៖ តាកននឹងកងពលលេខប៉ុន្មាន?

ពៅ ៖ កងពល៣២០ ។

ធានី ៖ ដល់ពេលក្រោយមក គេថាពូម៉េច?

ពៅ ៖ ខ្ញុំអត់រត់ទេ គេចោទយើងសង្ស័យថាមកនេះ ។

ធានី ៖ រត់មកណា?

ពៅ ៖ មកម៉ាឡៃ ។

ធានី ៖ តាមពិតពីអត់រត់ទេ?

ពៅ ៖ អត់ទេ ខ្ញុំអត់ដឹង ។

ធានី ៖ កាលនឹងម៉េចបានពូមកម៉ាឡៃ?

ពៅ ៖ នេះទើបខ្ញុំបានប្រពន្ធហើយទេ ។

ធានី ៖ ឆ្នាំប៉ុន្មានគេចោទពូ ចាប់ពូដាក់៣ខែ?

ពៅ ៖ ៨៣ ៨៤ ។

ធានី ៖ ចាប់ដាក់គុកនៅណា?

ពៅ ៖ នៅជិតភ្នំសាស្ត្រា នៅជិតគុកតាចាន់មួយនៅនឹង ។

ធានី ៖ ហើយតាចាន់នឹងគាត់អ្នកយាមគុកនៅនឹង?

ពៅ ៖ បាទ! គាត់ប្រធានគុក កាលគាត់ទោសតាឌុចឃើញគាត់នៅឆ្លើយបំភ្លឺដែរ ដែលគាត់កើតស្រែង ឈ្មោះតាអីដែលគាត់ប្រធានគុកនៅនឹង ។

ធានី ៖ គាត់នៅស្រុកណា?

ពៅ ៖ គាត់នៅភ្នំពេញ ។

ធានី ៖ គេអត់មានធ្វើបាបពួកណា គ្រាន់ឃុំឃាំង?

ពៅ ៖ អត់ទេ គ្រាន់ឃុំឃាំងអត់ឲ្យយើងទៅណា ។

ធានី ៖ តែពូម្នាក់ឯង មានអ្នកផ្សេង?

ពៅ ៖ អត់ទេ ក្នុងកងកាលនោះគេយក៤នាក់ ដែលគេសង្ស័យ ។

ធានី ៖ គេឃុំឃាំងដល់៣ខែ?

ពៅ ៖ ជិត៣ខែ តែឥឡូវបែកគ្នាអស់ ងាប់មួយ បែកគ្នាមួយ នៅគីឡូ៩២នាក់ ហើយអាមួយទៀតទៅជរំមួយគ្នាងាប់ ។

ធានី ៖ ឈ្មោះអីខ្លះ?

ពៅ ៖ ខ្ញុំមួយ ឈ្មោះអាថាមួយ ។

ធានី ៖ ថានៅណា?

ពៅ ៖ ឥឡូវងាប់ហើយ ទៅងាប់នៅសំឡូតទៅវៃនៅសំឡូត ។

ធានី ៖ ហើយ?

ពៅ ៖ អាពោតៗនៅគីឡូ៩រាល់ថ្ងៃ ។

ធានី ៖ ៣នាក់នឹង?

ពៅ ៖ បាទ! មួយទៀតទៅណាបាត់ហើយ អត់ដឹងចូលជរំ ។

ធានី ៖ ឈ្មោះអីគេ?

ពៅ ៖ ឈ្មោះ វានៅកងផ្សេងគ្នា ដល់អីចឹងអត់សូវស្គាល់វា ។

ធានី ៖ អ្នកណាអ្នកចោទរឿងនឹងសង្ស័យពូ?

ពៅ ៖ គេមានរត់ចេញពីនឹង គេនាំស្រីស្រឡាញ់គ្នាពួកដឹកជញ្ជូន ក៏គេសង្ស័យយើង ។

ធានី ៖ ថាយើងអ្នកនាំគេ?

ពៅ ៖ គេថាយើងអ្នកចង់មកដែរ ។

ធានី ៖ តែយើងអត់បានមក គេរត់បាត់?

ពៅ ៖ យើងអត់ដឹងយើងនៅមុខ ដល់ពេលមកវិញគេចាប់បញ្ជូន ។

ធានី ៖ ហើយអ្នកណាគេអ្នកចាប់?

ពៅ ៖ ក្នុងកងខ្លួនឯង គេបញ្ជូនមកកន្លែងតាចាន់ៗ ឈ្មោះគាត់គេហៅតាចាន់ៗ ប៉ុនឈ្មោះដើមគាត់មិនមែនតាចាន់ៗទេ ឈ្មោះដើមគាត់តាម៉ីៗ ។ គាត់កាលពីនោះ គាត់នៅក្នុងគុកដែរ រងពីតាឌុចដែរ ។

ធានី ៖ មកដល់នេះគាត់ធ្វើគុកដែរ?

ពៅ ៖ ដល់នេះធ្វើប្រធានៗ នៅដល់សព្វថ្ងៃ ដល់ផ្ដាច់ខ្លួនគាត់ខ្លាចគេធ្វើបាន គាត់រត់មកនេះៗ

ធានី ៖ ម៉េចរត់មកនេះ?

ពៅ ៖ មកនេះៗផ្ដាច់ខ្លួនមុន ដល់នោះក្រោយខ្លាចគេធ្វើបាប ខ្លាចអ្នកទោសគេសងសឹក គាត់រត់មកវិញ ដល់គេរៀបចំស្រួលបួល បានគាត់ទៅវិញៗ

ធានី ៖ គាត់ទើបទៅ៩០ជាង?

ពៅ ៖ អត់ទេ គាត់រត់នៅនេះឯង នៅសំពៅលូននេះៗ ស្រុកកំណើតខ្ញុំមិនសូវស្គាល់ទេ គ្រាន់ដឹងថា ចាន់នឹង ដែលគាត់ទៅបំភ្លឺតាឌុច ដែលឌុចនឹងឲ្យគាត់និយាយឲ្យអស់ៗ គាត់នៅនិយាយអត់អស់ គាត់លាក់ គាត់និយាយថាពីសម័យនឹងជីវិតអ្នកណាក៏ដូចអ្នកណា សម្លាប់បងប្អូនដូចគ្នា ដល់អីចឹងអ្នកណាក៏មានទោសដូចគ្នាគ្មានអ្នកណាគេចរួចពីសម័យនឹងៗ តាឌុច គាត់ថាឲ្យនិយាយឲ្យអស់រឿងផ្ទៃក្នុងនៅក្នុងគុកនឹង គាត់ថាយកស្លឹកអំពិលម៉ាស្លឹកមកបាំងដីរីៗ នៅនេះគេហៅតាចាន់ ព្រោះខ្ញុំមើលទូរទស្សន៍ៗ

ធានី ៖ សម័យខ្មែរក្រហមគាត់ធ្វើអី?

ពៅ ៖ គាត់រងប្រធានគុក គាត់ទទួលខុសត្រូវជាមួយតានឹងដែរនឹងៗ អឹយមិនស្គាល់ច្បាស់ម៉ងៗ កាលពីសម័យនឹងគាត់នៅកាប៉ុាល់ដើងទឹកទេ ដល់ពេលមកនេះ គាត់នៅជាមួយអ្នកធំច្រើន គាត់ច្បាស់ច្រើនៗ ខ្ញុំមិនសូវច្បាស់ទេៗ

ធានី ៖ តាចាន់នៅសាស្ត្រា បាត់ដំបង?

ពៅ ៖ បាទ!នៅខេត្តបាត់ដំបង នៅខាងនេះ នៅសំពៅលូននឹងៗ សាស្ត្រានឹងគ្រាន់ជាភ្នំ តែស្រុកៗសំពៅលូន ព្រោះភ្នំសាស្ត្រាក្រោយផ្សារនឹង អាភ្នំតូចនឹងគេហៅសាស្ត្រា ហើយភ្នំខាងនោះហៅសំពៅលូន ស្រុកៗសំពៅលូន ហើយមុខប្រកគេហៅគីឡូ១៣ មកគីឡូ១២ ដេញមកនេះៗ ចុងអូរល្ហា ចុងស្រុកម៉ាឡៃជាប់គ្នាៗ

ធានី ៖ គីឡូ១៣មាត់ប្រកអី?

ពៅ ៖ មាត់ប្រកទៅថៃៗ

ធានី ៖ នៅប្រកនឹងមានកាកបាទក្រហមអីទេ?

ពៅ ៖ តាំងពីដើមមកឃ្លាំងធំនៅនឹង គ្រាប់រំសេវ អង្ករ ទឹកត្រី វាចេញមកខ្លាំង ហើយពួកនារីដឹកជញ្ជូនមកនឹងច្រើនៗ

ធានី ៖ ពូថាមានកាកបាទក្រហមជួយៗពីកន្លែងនឹង ឬជួយខាងប្រកយើង?

ពៅ ៖ កាកបាទគេជួយខាងនេះខ្លាំង ប៉ុនអំណោយរបស់របជួយតាមកងទ័ពៗ

ធានី ៖ កាកបាទជួយគីឡូ១៣ដែរ?

ពៅ ៖ អត់សូវជួយទេ កាលជំនាន់យើងច្បាំងជួយប្រកខាងនេះជាង ។

ធានី ៖ ពូថាសម្ភារៈខាងនោះវិញ?

ពៅ ៖ បាទ! អានឹងសម្ភារៈយោធា ។

ធានី ៖ យោធាខាងនោះ ដល់ខាងនេះសម្រាប់ហូបចុក?

ពៅ ៖ បាទ! អានេះយោធាដែរ តែកាកបាទវាជួយច្រើនជាង ។

ធានី ៖ ខាងនោះមិនមែនសម្ភារៈកាកបាទទេ ខាងផ្សេងទៀត?

ពៅ ៖ បាទ!

ធានី ៖ ដឹងខាងណាទេ?

ពៅ ៖ ខាងតាកន កាលនឹងមានកងពលផ្សេង ហើយខាងនេះខាងតាហុង តាភាពម៉ាកងពល ។

ធានី ៖ ខាងនេះកងពលផ្សេងគេជួយផ្សេង ខាងនោះគេជួយផ្សេង?

ពៅ ៖ អត់ទេ រឿងសម្ភារៈយោធាតែមួយ ប៉ុន្តែគ្រាន់កាកបាទគេជួយនៅនេះមានប្រជាជន ហើយទៅខាងនោះអត់សូវមានប្រជាជនមានកងទ័ព ។

ធានី ៖ គាត់នឹងជាអនុរបស់ឌុច?

ពៅ ៖ បាទ! កាលនឹងត្រូវជាម៉េច ត្រូវជាអនុ ត្រូវជារងទីប៉ុន្មានទេ យើងអត់ដឹង ។ គាត់ចាស់ខ្ពស់ស្តើង គាត់ពាក់ស្រោមដៃ ព្រោះខ្លួនគាត់ដោះមកដូចកូនកណ្តុរ ក្រហមរបក់ ។ កាលជំនាន់លន់ នល់នឹង គេចាប់គាត់ថាគាត់ទាក់ទងជាមួយខ្មែរក្រហម ដល់អីចឹងគេប្រកមិនដឹងប្រកស្អី ប្រតិកម្មស្បែកចេញមក គាត់នៅក្នុងគុករហូតសម័យ៣ឆ្នាំ អ្នកទទួលខុសត្រូវមួយដែរ ។

ធានី ៖ តែគេហៅតាចាន់ៗ?

ពៅ ៖ ព្រោះឈ្មោះគាត់នៅនេះគេហៅតាចាន់ ។

ធានី ៖ ក្រៅពីគាត់ ពូមានស្គាល់អ្នកផ្សេងទៀតដែរ ធំៗដែរ គាត់ធ្វើការនៅសម័យខ្មែរក្រហម?

ពៅ ៖ ខ្ញុំអត់ដឹង ។

ធានី ៖ ចំពោះចិត្តពូធ្លាប់ឆ្លងកាត់ច្រើនជំនាន់ហើយ តើវាមានភាពខុសប្លែងគ្នាយ៉ាងម៉េចពីម៉ាជំនាន់ទៅរហូតដល់ឥឡូវ?

ពៅ ៖ វាខុសប្លែកគ្នាបើមែនទែនយើងមិនគិតស្មានថាយើងបានរស់រានមានជីវិតដល់សព្វថ្ងៃ បើតាមតែឆ្លងកាត់ពេលលំបាកច្បាំងគ្នា យើងមិនបានគិតថាយើងរស់ដល់សព្វថ្ងៃ ។ និយាយមែនទែនទៅវារំភើប ដេកគិតរាល់ មិនគួរបានរស់ដល់សព្វថ្ងៃ ។

ធានី ៖ មកដល់ពូយល់ថាម៉េចដែរ ការរស់នៅរាល់ថ្ងៃវាខុសប្លែកពីការពីមុនយ៉ាងម៉េច ដែលពីមុនជាព្រៃ ហើយឥឡូវជាផ្ទះ ជាភូមិករ?

ពៅ ៖ ដល់ពេលឥឡូវយើងសប្បាយ យើងកើតភូមិស្រុក ធ្វើជាក្រុមប្រក់ស្បូវ ហើយដើរគ្មានផ្លូវដើរ ជាន់ម៉ាជើងៗផ្លូវដល់យូរខែវស្សាដូចជណ្តើរ មានពូនដីម៉ាគំនូកៗតាមយើងដើរ ។ ដល់ពេលខែវស្សាគេចូកចាល ដើរតៗគ្នាដីនឹងដុំៗពូតៗតគ្នា ។ លំបាកៗ ប៉ុនការហូបចុកវាអត់ភ័យ ។ ដល់ខែរបបបើក អ្នកទៅមុខទៅៗ ដល់វេណផ្លូវក៏ផ្លូវចុះឡើង ប្រពន្ធកូនអត់មានភ័យខ្លាច ឈឺថ្កាត់ពេទ្យ ប្រពន្ធកូនឈឺមើលឱតដល់ថ្នាំក៏សំបូរឃ្លាំងៗល្អៗ ឈឺអីក៏ពេទ្យប្តីវៃទៅមុខក៏អត់មានបារម្ភដែរ ។ បើមកដូចឥឡូវ បើយើងមិនមានលុយពិបាកដែរសង្គមគេ បើយើងមិនប្រឹងអត់ហើយ ។

ធានី ៖ ពូមានអីចង់បន្ថែម ឬឆ្លល់អី មានអីបន្ថែមក្រៅពីអីដែលខ្ញុំអត់សួរ?

ពៅ ៖ មែនទែនទៅវាគ្រាន់ថាយើងធ្វើបានល្អសម្រាប់យើង ធ្លាប់ជួបលំបាកដល់ពេលឥឡូវនេះប្រែមកស្រួល យើងសប្បាយចិត្ត ។

ធានី ៖ អរគុណពូច្រើន ។

«ចប់»